# កូនជ្រូកច្រើន កាន់តែថ្លោស និង រឹងមាំ



# ១.   កូនជ្រូកច្រើនពេលផ្តាច់ដោះ

# ក. មូលដ្ឋានគ្រឹះនៃការបន្តពូជ

១.ប្រដាប់បន្តពូជមេជ្រូក

- **អូវែ** បង្កើតអូវុល (មេជីវិតញី)
- **ស្បូន** ជាកន្លែងដែលទារកលូតលាស់
- ការនៅជិតគ្នារវាងប្លោកនោម និងយោនី បង្កគ្រោះថ្នាក់ដល់ការចម្លងមេរោគ



# ក. មូលដ្ឋានគ្រឹះនៃការបន្តពូជ

## ១.ប្រដាប់បន្តពូជមេជ្រូក

ស្បូន និងប្លោកនោម




យោនី



# ក. មូលដ្ឋានគ្រឹះនៃការបន្តពូជ

## ២.ប្រដាប់បន្តពូជជ្រូកឈ្មោល



- **ពងស្វាសៈ** ត្រូវមានទំហំប៉ុនគ្នា, មាំមួន, គ្មានស្លាកស្នាម ។ ពងស្វាសមានភាពទន់ និងមានសីតុណ្ហភាពត្រជាក់ ។
- **លិង្គៈ** ត្រូវស្អាត គ្មានខ្ទុះ និងដំបៅ ។

# ក. មូលដ្ឋានគ្រឹះនៃការបន្តពូជ

## ២. ប្រដាប់បន្តពូជជ្រូកឈ្មោល

ពងស្វាសល្អរបស់ជ្រូកបារ៉ាំងក្មេង



ការពិនិត្យលិង្គ



# ក. មូលដ្ឋានគ្រឹះនៃការបន្តពូជ

## ៣.ការបង្កាត់

- ចាំបាច់ត្រូវស្វែងរកពេលវេលាល្អ ក្នុងការបង្កាត់
- យោនីឡើងក្រហម
- មេជ្រូកនៅស្ងៀម នៅពេលយើងសង្កត់លើខ្នងវា
- ប្រសិនបើយើងឃើញសញ្ញាបែបនេះនៅពេលព្រឹក ត្រូវបង្កាត់ពេលល្ងាច
- ប្រសិនបើយើងឃើញសញ្ញាបែបនេះនៅពេល ល្ងាច ត្រូវបង្កាត់ពេលព្រឹកស្អែក





# ក. មូលដ្ឋានគ្រឹះនៃការបន្តពូជ

## ៣.ការបង្កាត់

ការបង្កាត់តាមធម្មជាតិ



ការបង្កាត់នឹងធ្វើតាមបែបសិប្បនិម្មិត



# ២. តើត្រូវធ្វើដូចម្តេចដើម្បីទទួលបានកូនជ្រូកកាន់តែច្រើន?



# ១.កូនជ្រូកច្រើនក្នុងស្បូន

**១.១ មេជ្រូកស្ថិតក្នុងស្ថានភាពល្អ:** មេជ្រូកល្អ គឺមេជ្រូកដែលមានរាងដូចរូបលេខ ៣។ មេជ្រូកនេះ

អាចផលិតអូវ៉ុលបាន គ្រប់គ្រាន់ និង សុកល្អ។



# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.១ មេជ្រូកស្ថិតក្នុងស្ថានភាពល្អ

ដងខ្លួនមិនល្អ



ដងខ្លួនល្អ



# ១.កូនជ្រូកច្រើនក្នុងសម្បូន

## ១.២ សម្បូនស្ថិតក្នុងស្ថានភាពល្អ

**តួនាទីសម្បូនៈ**

- អូវែផលិតអូវុល នៅពេលដែលមេជ្រូករកឈ្មោល។ អូវុលទាំងនេះ ធ្វើដំណើរមកជួបមេជីវិតឈ្មោលតាមបំពង់មួយ ដែលហៅថា បំពង់អូវុល។ ក្នុងករណីដែលមានឆ្លងមេរោគ បំពង់ទាំងនេះត្រូវករខូច អូវុលមិនអាចទៅកាន់សម្បូនហើយ មេជ្រូកត្រឡប់រកឈ្មោលជាថ្មីម្តងទៀត។

- បន្ទាប់ពីបង្កកំណើត អឺប្រ៊ីយ៉ុង (កូនក្នុងផ្ទៃ) លូតលាស់ក្នុងសម្បូន។ ក្នុងករណីការឆ្លងមេរោគ សុកត្រូវរងការបំផ្លាញ និង មិនអាចចិញ្ចឹម អឺប្រ៊ីយ៉ុង (កូនក្នុងផ្ទៃ) ឱ្យក្លាយទៅជាកូនជ្រូក។

អឺប្រ៊ីយ៉ុង (កូនក្នុងផ្ទៃ) មិនអាចកាច់សំបុកក្នុងសុកបានទេ ធ្វើឱ្យកូនមួយសំបុកមានចំនួនតិចពី ៣ ទៅ ៦

អឺប្រ៊ីយ៉ុង (កូនក្នុងផ្ទៃ) នឹងងាប់មួយខែក្រោយមក ព្រោះលក្ខណៈរបស់សុកមិនល្អ នឹងធ្វើឱ្យកូនជ្រូកងាប់មិនរលួយ។

អឺប្រ៊ីយ៉ុង (កូនក្នុងផ្ទៃ) អាចរស់ប៉ុន្តែមិនទទួលការចិញ្ចឹមគ្រប់គ្រាន់ពីសុក ហើយធ្វើឱ្យកូនជ្រូកកើតមកតូច ហើយខ្សោយ

# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.២ ស្បូនស្ថិតក្នុងស្ថានភាពល្អ




- ៧: អូវែដែលបង្កើតអូវុល
- ៦: បំពង់អូវុលសំរាប់អូវុលធ្វើដំណើរឆ្លងកាត់មកកាន់ស្បូន
- ៤: ស្បូនជាកន្លែងដែលកូនជ្រូកលូតលាស់រហូតដល់កើត

# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.២ ស្បូនស្ថិតក្នុងស្ថានភាពល្អ

ស្បូនមេជ្រូកពេលរកឈ្មោល ។ អូវែផលិតអូវុល ។



# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.២ ស្បូនស្ថិតក្នុងស្ថានភាពល្អ

ស្បូនមេជ្រូកក្រោយផើម២ខែ។ កូនជ្រូក១១ក្បាល កំពុងលូតលាស់នៅខាងក្នុង។



# ១.កូនជ្រូកច្រើនក្នុងសម្បូន

## ១.២ ស្បូនស្ថិតក្នុងស្ថានភាពល្អ

រូបកូនជ្រូក និងកូនជ្រូកនៅក្នុងស្បុករយៈពេល២៨ថ្ងៃក្រោយផើម ក្នុងស្ថានភាពល្អ



# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.២ ស្បូនស្ថិតក្នុងស្ថានភាពល្អ

កូនជ្រូក និងសុក២ខែក្រោយផើម ។ ស្បូន និងសុកស្ថិតក្នុងស្ថានភាពល្អ ។



# ១.កូនជ្រូកច្រើនក្នុងសម្បុក

## ១.៣ ជំងឺរលាកស្បូន

- ជំងឺរលាកស្បូនៈ ពេលដែលស្បូនឆ្លងមេរោគ បាក់តេរីលូតលាស់ បំផ្លាញស្បូន និងពេលខ្លះបង្កខ្ទុះ (គេអាចមើលឃើញនៅពេលមានហូរខ្ទុះតាមយោនី)

**ស្បូនឆ្លងមេរោគៈ**

**ក្រោយពេលកើតកូន** ព្រោះសុកធ្លាក់មិនអស់ ឬមេជ្រូកមិនស្អាត ឬកើតកូននៅកន្លែងកខ្វក់ ។

**កំឡុងពេលបង្កាត់** ឆ្លងមេរោគពីជ្រូកបាដែលមានមេរោគនៅប្រដាប់បន្តពូជ ។ ការឆ្លងមេរោគ ដោយសារប្រលែកនោម មានមេរោគ ។

ការឆ្លងមេរោគ និងស្ថានភាពមិនល្អរបស់ស្បូន តែងតែនាំទៅការខ្សោយការបន្តពូជៈ ត្រឡប់ទៅរកឈ្មោល, កូនតិចក្នុង១សំបុក, ការងាប់មិនរលួយកូន ឬកូនកើតមកខ្សោយ

# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៣ ជំងឺរលាកស្បូន

- ខ្ទុះ ហូរចេញពីយោនី



# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៣ ជំងឺរលាកស្បូន

ស្បូនស្ថានភាពមិនល្អ ដោយការចម្លងមេរោគ។



# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៣ ជំងឺរលាកស្បូន

ក្នុងស្បូននេះ មានកូនជ្រូកតែ៥ នៅខាងក្នុងមានទំរង់ខុសៗគ្នា និង មានកូនខ្លះងាប់មិនរលួយ ។



# ១.កូនជ្រូកច្រើនក្នុងសម្បុក

## ១.៣ វិធីលាកស្បូន

**ការការពារ**

**មុនពេលកើតកូន:**



- ពិនិត្យលិង្គរបស់ជ្រូកបា មុនពេលបង្កាត់
- លាងយោនី និងជូតសម្អាតឱ្យស្ងួត មុនពេលបង្កាត់
- លាងមេជ្រូក (ជាពិសេសយោនី) នៅពេលជិតកើតកូន
- លាង និងបាញ់រម្ងាប់មេរោគក្នុងទ្រុង
- នៅពេលមេជ្រូកចាប់រកឈ្មោលម្តងទៀត លាយអង់ទិប៊ីយ៉ូទិច (ទ្រីមេតូព្រីម (Trimetoprim) +ស៊ុលហ្វា (sulfa) ឬអាម៉ុកស៊ីលីន (Amoxicillin)) ក្នុងចំណីបន្ទាប់ពីថ្ងៃបង្កាត់ ឱ្យស៊ីរយៈពេល ៧ថ្ងៃ

  ឬ ចាក់អាម៉ុកស៊ីលីនដែលមានសកម្មភាពយូរ (Amoxicillin LA) រៀងរាល់ពីរថ្ងៃម្តង ចំនួន៣ដង

# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៣ ជំងឺរលាកស្បូន

**ការការពារ**

**<u>ក្រោយពេលកើតកូនៈ</u>**

- ត្រូវប្រាកដថា សុកធ្លាក់អស់ ប្រសិនបើធ្លាក់មិនអស់ ត្រូវចាក់អុកស៊ីតុកស៊ីន ២ សេសេ នៅពេលកើតកូនរួចរាល់ ( យូរបំផុត ២ម៉ោងក្រោយមក)
- ប្រសិនបើលូកដៃជួយបង្កើតកូន ត្រូវចាក់អង់ទីប៊ីយ៉ូទិច ( ទ្រីមេតូព្រីម (Trimetoprim) ជាមួយ ស៊ុលហ្វា (Sulfa)) ក្នុងរយៈពេល ៣ ថ្ងៃក្រោយពេលកើតឱ្យវា
- ២-៣ថ្ងៃក្រោយពេលកើត ពិនិត្យកំដៅក្នុងខ្លួនជ្រូកនៅពេលព្រឹក ។ ប្រសិនបើក្តៅលើស ៤0 អង្សាសេ ចាក់អង់ទីប៊ីយ៉ូទិច
- ការហូរចេញវត្ថុរាវ ២-៣ថ្ងៃក្រោយពេលកើតកូនជាការធម្មតា ប៉ុន្តែត្រូវច្បាស់ថាគ្មានក្លិនស្អុយ ។ ប្រសិនបើឃើញមានការហូរចេញវត្ថុរាវ ដោយមានពណ៌ប្រផេះ ខ្ទុះ ឬក៏ធុំក្លិនអាក្រក់ ត្រូវចាក់ប្រូស្តាហ្គ្លង់ឌីន *(Prostaglandin)* ជាមួយអង់ទីប៊ីយ៉ូទិច ។ ប្រូស្តាហ្គ្លង់ឌីន *(Prostaglandin)* នឹងជួយធ្វើឱ្យធ្លាក់សារធាតុកខ្វក់ក្នុងស្បូន ។

# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៣ ជំងឺរលាកស្បូន

### ការព្យាបាលជំងឺរលាកស្បូន

វាមានការពិបាកក្នុងការសន្និដ្ឋានថា ជាជំងឺរលាកប្លោកនោម ឬក៏ជំងឺរលាកស្បូន នៅពេលដែលយើងគ្រាន់តែឃើញមានការហូរខ្ទុះចេញពីយោនី ប៉ុន្តែអ្នកត្រូវតែព្យាបាល ទោះបីវាមើលទៅមិនឈឺក៏ដោយ ។

- អង់ទីប៊ីយ៉ូទិចៈ ចាក់អង់ទីប៊ីយ៉ូទិចយ៉ាងតិច ៥ថ្ងៃ ។

  - ប្រសិនបើកំដៅមិនខ្ពស់ទេ ចាក់ទ្រីមេតូព្រីម(Trimetoprim) ជាមួយ ស៊ុលហ្វា (Sulfa) ឬអាម៉ុកស៊ីលីន (Amoxicillin)

  - ប្រសិនបើកំដៅខ្ពស់ អង់រ៉ូហ្លុកសាស៊ីន (Enrofloxacine)

ប្រសិនបើមេជ្រូកមិនផើម (វាប្រាកដ ១០០%) ត្រូវចាក់ៈ

- ប្រូស្តាតហ្គ្លង់ឌីន (Prostaglandin) (ឌីណូលីទិច (Dinolytic) )ថ្នាំនេះជួយបើកកស្បូន និងកន្ត្រាក់ស្បូនឱ្យបញ្ចេញខ្ទុះ និងវត្ថុធាតុកខ្វក់ ។

អុកស៊ីតុកស៊ីន *(Ocytocine)* គ្មានប្រសិទ្ធភាព ក្នុងការធ្វើអោយកន្ត្រាក់ស្បូន និងព្យាបាលជំងឺរលាកស្បូនទេ ។ វាមានប្រសិទ្ធភាពតែពេលកើត និង ១ ឬ ២ម៉ោងក្រោយពេលកើត ។

# ១.កូនជ្រូកច្រើនក្នុងសម្បូន

## ១.៤ ទឹកកាមដែលមានគុណភាពល្អ

ទឹកកាម ផ្ទុកទៅដោយមេជីវិតឈ្មោលដែលផលិតដោយពងស្វាស ។

ដើម្បីឱ្យការបង្កកំណើតបានល្អ និងផលិតកូនជ្រូកបានច្រើន គឺទឹកកាមត្រូវតែមានគុណភាពល្អៈ

- មេជីវិតឈ្មោលច្រើន
- មេជីវិតឈ្មោលមានចលនាខ្លាំង
- មេជីវិតឈ្មោល មានសភាពប្រក្រតី ( ធម្មតា)



# ១.កូនជ្រូកច្រើនក្នុងសម្បុក

## ១.៤ ទឹកកាមដែលមានគុណភាពល្អ

- ភាពប្រក្រតី ( ធម្មតា) និងភាពមិនប្រក្រតីរបស់មេជីវិតឈ្មោល នៅពេលយើងពិនិត្យទឹកកាម ដោយមីក្រូទស្សន៍។





# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៤ ទឹកកាមដែលមានគុណភាពល្អ

- ទឹកកាមល្អ



- ទឹកកាមមិនល្អ



# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៤ ទឹកកាមដែលមានគុណភាពល្អ

### បញ្ហាដែលមានឥទ្ធិពលដល់គុណភាពទឹកកាម

- <u>គ្រុនក្តៅ:</u> នៅពេលដែលជ្រូកបាមានសីតុណ្ហភាពលើសពី ៤០ អង្សាសេ ពី-បីថ្ងៃ ហើយ ៣អាទិត្យក្រោយមក ជ្រូកបាសះស្បើយឡើងវិញ។ ជ្រូកបានេះមានសុខភាពល្អ ប៉ុន្តែស្ពៃម វាមិនអាចបង្កកំណើតបាន (គ្មានមេជីវិតឈ្មោល)

  បើចាំបាច់ ត្រូវចាក់ថ្នាំដើម្បីបញ្ចុះកំដៅជ្រូកបា ដូចជា អាណាហ្សាំង (Analgine)/ កាម៉ាហ្សីន (Calmagine)/ កេតូហ្វែន (Ketofen) ដែលមានប្រសិទ្ធភាពតែ ១ ទៅ ២ម៉ោងប៉ុណ្ណោះ។ ប៉ារ៉ាសេតេម៉ុល (Paracetamol) មានប្រសិទ្ធភាពរយៈពេល ៦ម៉ោង ហើយតុលហ្វេដីន (Tolfedine) មានពី ២៤-៤៨ ម៉ោង។

- <u>អាកាសធាតុក្តៅ:</u> ពេលសីតុណ្ហភាពក្តៅ ពងស្វាសនៅខាងក្រៅខ្លួនជ្រូកបញ្ឈប់ការផលិតមេជីវិតឈ្មោល ហើយគុណភាពរបស់មេជីវិតឈ្មោលធ្លាក់ចុះ (ខែមីនា ដល់ឧសភា)។

  ត្រូវលាយវីតាមីនសេ ១ក្រាមក្នុងចំណីរៀងរាល់ថ្ងៃ។

- <u>ដំបៅពងស្វាស:</u> ប្រសិនបើពងស្វាសមានរបួស ជ្រូកបាមិនអាចបង្កកំណើតបាន។

  ចាក់តេត្រាស៊ីគ្លីន (Tetracycline) និងជូតសម្អាតស្បែកពង។

# ១.កូនជ្រូកច្រើនក្នុងសម្បូន

## ១.៤ ទឹកភាមដែលមានគុណភាពល្អ

### ជំងឺដែលអាចប៉ះពាល់ដល់គុណភាពស្ពែម

- ជម្ងឺប្រ៊ុយសែលឡូស (Brucellosis)

- រោគសញ្ញាសំខាន់ គឺរលាកសន្លាក់ ពងស្វាសរីកធំ ហើយមានបូស។
- ជ្រូកបាមិនអាចបង្កកំណើតបាន
- នៅពេលបង្កាត់ ជ្រូកបាចម្លងទៅជ្រូកមេ ហើយបង្កឱ្យរលូតកូន
- ជម្ងឺនេះអាចឆ្លងទៅមនុស្ស
- បញ្ហាដែលសត្វជួបប្រទះខ្លះ អាចធ្វើឱ្យពងស្វាសរីកធំ ប៉ុន្តែទន់មិនប៉ះពាល់ដល់ការបន្តពូជ

ដើម្បីឱ្យប្រាកដថាវាជាជម្ងឺប្រ៊ុយសែលឡូស: ត្រូវវិភាគឈាមនៅ មជ្ឈមណ្ឌលជាតិស្រាវជ្រាវ ផលិតកម្ម និង បសុពេទ្យាបាល *(NAHPIC)*



# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៥ ការគ្រប់គ្រងមេជ្រូកដើមឱ្យបានល្អ

### ធ្វើមិនឱ្យជ្រូកស្ត្រេស

- អំប្រីយ៉ុង (កូននៅក្នុងផ្ទៃ) នឹងស្ថិតនៅក្នុងសុកប្រហែល ១០ថ្ងៃ បន្ទាប់ពីបង្កាត់។ ក្នុងកំឡុងពេលនេះ
  - មិនត្រូវផ្លាស់ប្តូរទីកន្លែងរបស់មេជ្រូកឡើយ។
  - ការពារមិនឱ្យមេជ្រូកខាំគ្នា
  - ប្រសិនបើមានមេជ្រូកច្រើនក្នុងទ្រុងតាមដានការខាំ របស់
  - គ្រប់គ្រងលាមកសត្វ
  - បាញ់ប៉ីយុតុក (Butox)

<u>ព្យាបាលអង្កែះ</u>

ចាក់អ៊ីវែមិចទីន (Ivermectine)



ត្រូវដាក់មេជ្រូកមានផ្ទៃពោះ នៅកន្លែងស្ងាត់ ក្នុងម្លប់

# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៥ ការគ្រប់គ្រងមេជ្រូកដើមឱ្យបានល្អ

- ការរំខានដោយរុយ មូស




- អង្កែ



# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៥ ការគ្រប់គ្រងមេជ្រូកដើមឱ្យបានល្អ

### ការផ្គត់ផ្គង់ចំណីបានគ្រប់គ្រាន់

- **ការផ្តល់ចំណី**

មេជ្រូកផើមត្រូវឱ្យចំណីដោយមានការកំណត់ត្រឹមត្រូវ ប៉ុន្តែត្រូវការជាតិសសៃដើម្បីឱ្យវាឆ្អែត និងការពារមិនឱ្យក្ញៀន ដែលនាំឱ្យចលនាឈាមរត់ល្អក្នុងស្បូន។

ជ្រូកមេត្រូវការវីតាមីន និងសារធាតុរ៉ែ។ ត្រូវលាយប្រេមិចក្នុងចំណី

- **ការផ្តល់ទឹក**

ការផ្តល់ទឹកគ្រប់គ្រាន់យ៉ាងតិច ៣០លីត្រ។

ការផ្តល់ទឹកបានត្រឹមត្រូវល្អ ជៀសវាងបញ្ហារលាកប្លោកនោម និងរលាកស្បូន។



# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៦ បរាជ័យនៃការមានផ្ទៃពោះ (ដើម)

**កូនជ្រូកខាប់ឡើងស្វិត:** ពេលដែលកូនជ្រូកងាប់ក្នុងស្បូន ៣៥ថ្ងៃក្រោយពេលផើម ។

កូនក្នុងផ្ទៃឡើងស្ងួត និង ឡើងពណ៌ត្នោតចាស់ ។



# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៦ បរាជ័យនៃការមានផ្ទៃពោះ (ដើម)

**កូនជ្រូកខាប់ឡើងស្វិត**

មេរោគប៉ារ៉ូ វាតត្បាតគ្រប់កសិដ្ឋាន

គ្មានរោគសញ្ញាចំពោះមេជ្រូក ប៉ុន្តែៈ

- ត្រឡប់ទៅរកឈ្មោល
- កូនងាប់ក្រៀមស្វិត ហើយនៅពេលកើតមានទំហំខុសៗគ្នា
- មិនរលូត

គ្មានថ្នាំការព្យាបាល

- ត្រូវចាក់វ៉ាក់សាំង ២អាទិត្យមុនពេលបង្កាត់ ដើម្បីការពារជម្ងឺប៉ារ៉ូ

**អូសេស្គី** (Aujesky) ជម្ងឺឆ្កួតជ្រូកក្លែងក្លាយអាចឱ្យកូនងាប់ក្រៀមស្វិត ប៉ុន្តែៈ

- កូនងាប់ក្រៀមស្វិតមានទំហំប៉ុនគ្នា
- រោគសញ្ញាសរសៃប្រសាទ កើតមានចំពោះជ្រូកទើបកើត

# ១.កូនជ្រូកច្រើនក្នុងសម្បូន

## ១.៦ បរាជ័យនៃការមានផ្ទៃពោះ (ដើម)

**ការរលូតកូន:** ការកើតកូន មុនការកំណត់



# ១.កូនជ្រូកច្រើនក្នុងសម្បុក

## ១.៦ បរាជ័យនៃការមានផ្ទៃពោះ (ដើម)

**ការរលូតកូន**

- <u>ជំងឺអូសេស្គី (Aujesky) ជម្ងឺឆ្កួតជ្រូកក្លែងក្លាយ</u>

រោគសញ្ញាដទៃទៀត: បន្ទាប់ពីកើត កូនជ្រូកបង្ហាញបញ្ហាសសៃប្រសាទ : ប្រកាច់ ហើយងាប់ភ្លាម។

គ្មានថ្នាំព្យាបាល។ ចាក់វ៉ាក់សាំងមេជ្រូកដើម។

- <u>ជំងឺប្រ៊ុយសែលឡូស</u>

រោគសញ្ញាដទៃទៀត: រលាកស្បូនញឹកញាប់ជាមួយខ្ទុះ

ព្យាបាលជាមួយអង់ទិប៊ីយ៉ូទិច: តេត្រាស៊ីគ្លីន (Tetracycline) រយៈពេល ១អាទិត្យ

- <u>ជំងឺឡិបតូស្ពីរ៉ូស</u>

រោគសញ្ញាដទៃទៀត: ប្រសិនបើគ្មានរលូតទេ កូនជ្រូកមានភ្នែកពណ៌លឿង

ព្យាបាលជាមួយអង់ទិប៊ីយ៉ូទិច: ប៉េងស្ត្រិប (PenStrep) រយៈពេល ៥ថ្ងៃ

- <u>ជំងឺប៉េស្តជ្រូក</u>

រោគសញ្ញាដទៃទៀត: ឡើងកំដៅ។ ជួនកាល មានឈាមក្រោមស្បែក

គ្មានថ្នាំព្យាបាល។ ចាក់វ៉ាក់សាំង មេជ្រូកដើម។

# ១.កូនជ្រូកច្រើនក្នុងសម្បុន

## ១.៧ ជំងឺដែលប៉ះពាល់ដល់ការមានផ្ទៃពោះ (ដើម)

- **ឈឺជើង:** មេជ្រូកពិបាកដើរ ឬឈរ





# ១.កូនជ្រូកច្រើនក្នុងសម្បូន

## ១.៨ បញ្ហាសត្វជួបប្រទះ ដែលប៉ះពាល់ដល់ការមានផ្ទៃពោះ (ដើម)

**ឈឺជើង**

នៅពេលមេជ្រូកមិនអាចឈរ ពួកវានឹងមិនអាចផឹកទឹកគ្រប់គ្រាន់ និងប្រឈមមុខបញ្ហារលាកប្លោកនោម និងក្រោយមករលាក ស្បូន។

នៅពេលមេជ្រូក ដេកពេញ ១ថ្ងៃ វាប្រឈមមុខចលនាឈាមមិនល្អ ប៉ះពាល់ដល់សុក។

ការព្យាបាល

បញ្ជ្រកទឹក ដើម្បីឱ្យច្បាស់ថា វាអាចផឹកទឹក បាន៣០លីត្រក្នុង ១ថ្ងៃ

ប្រសិនបើមេជ្រូក អាចទ្រាំនឹងការឈឺនេះ ចាក់ថ្នាំបញ្ចុះកំដៅ ដូចជា ផេនីលប៊ុយតាសូន (Phenylbutazone), តុលហ្វេឌីន (Tolfedine) ។ កុំប្រើដិចសាមេតាសូន (Dexamethasone) លើជ្រូកផើម។

ប្រសិនមានការរលាកក្រចក, សន្លាក់.........ចាក់អង់ទីប៊ីយ៉ូទិចដូចជា អាម៉ុកស៊ីលីនមានសកម្មភាពយូរ (Amoxicilline LA) ឬទ្រីមេតូព្រីម (Trimetoprim) + ស៊ុលហ្វា (Sulfa) ឬទីឡូស៊ីន (Tylosin)

ជំងឺអុតក្ដាម បង្កឱ្យសត្វឈឺជើង ហើយការព្យាបាលមិនសូវមានប្រសិទ្ធភាពទេ។

ជាញឹកញាប់ បញ្ហាឈឺជើងនេះបណ្ដាលមកពីកំរាលទ្រុងមិនល្អ។

*ការជួសជុលកំរាលឡើងវិញ វាថោកជាងការព្យាបាល ។*

# ១.កូនជ្រូកច្រើនក្នុងសម្បូន

## ១.៨ បញ្ហាសត្វជួបប្រទះ ដែលប៉ះពាល់ដល់ការមានផ្ទៃពោះ (ដើម)

**ឈឺជើង:** រោគសញ្ញាជម្ងឺអុតក្តាម ដែលបង្កឱ្យបញ្ហាលើជើងធ្ងន់ធ្ងរ





# ១.កូនជ្រូកច្រើនក្នុងស្បូន

## ១.៨ បញ្ហាសត្វជួបប្រទះ ដែលប៉ះពាល់ដល់ការមានផ្ទៃពោះ (ដើម)

### ការផ្តល់ភាពងាយស្រួលសំរាប់មេជ្រូកផឹកទឹកនៅពេលវាឈឺជើង



# ១.កូនជ្រូកច្រើនក្នុងសម្បូន

## ១.៨ បញ្ហាសត្វជួបប្រទះ ដែលប៉ះពាល់ដល់ការមានផ្ទៃពោះ (ដើម)

### ក្តៀន

វាចាំបាច់ណាស់ ក្នុងការពារកុំឱ្យជ្រូកក្តៀន ជាពិសេសនៅសប្តាហ៍ ចុងក្រោយនៃការមានគភ៌ ។ ប្រសិនបើវាក្តៀន ជាឱកាសល្អសំរាប់ពួក អីកូលី រីកលូតលាស់ ។ ការក្តៀនមុនពេលកើត នាំឱ្យមាន ការពិបាកកើត កូន និងជាញឹកញាប់បង្កជម្ងឺលាសដោះ ជម្ងឺរលាកស្បូន និងជម្ងឺខ្វះទឹកដោះ ។

មេជ្រូកក្តៀន ជាញឹកញាប់ពីព្រោះ

- ជ្រូកស៊ីចំណីមិនគ្រប់គ្រាន់
- កំដៅក្នុងខ្លួនខ្ពស់ ឬក៏កសិករមិនផ្តល់ចំណីគ្រប់គ្រាន់

ព្យាបាល:

មេជ្រូកត្រូវដើរ

ត្រូវផ្តល់ បន្លែពណ៌បៃតង

លាយចំណីជាមួយប្រេងប៉ារ៉ាហ្វីន






# ១.កូនជ្រូកច្រើនក្នុងសម្បូន

## ១.៨ បញ្ហាសត្វជួបប្រទះ ដែលប៉ះពាល់ដល់ការមានផ្ទៃពោះ (ដើម)

### រលាកប្លោកនោម

អាចសម្គាល់ឃើញនៅពេលដែលទឹកនោមចុងក្រោយមានលាយខ្ទុះ។

យើងឃើញតំណក់ទឹកពណ៌សនៅជាប់យោនី ឬនៅលើកំរាលទ្រុងខាងក្រោយមេជ្រូក។

ភាគច្រើនមេជ្រូកមើលទៅមានសុខភាពល្អ

ប៉ុន្តែវាត្រូវព្យាបាលជាចាំបាច់ដោយចាក់ ឬលាយក្នុង ចំណីនូវទ្រីមេតូព្រីម (Trimetoprim) ជាមួយស៊ុលហ្វា (Sulfa) រយៈពេល ៥ ទៅ៧ថ្ងៃ

ត្រូវច្បាស់ថា មេជ្រូកអាចផឹកទឹកគ្រប់គ្រាន់



# ២.កូនជ្រូកច្រើនកើតរស់
## ២.១ ការរៀបចំបង្កើតកូនបានល្អ

- ដើម្បីជួយមេជ្រូក ពេលកើតកូន វាចាំបាច់ក្នុងការគិតថ្ងៃខែកើត: ១១៤ថ្ងៃ
- នាំមេជ្រូកទៅទ្រុង ឬកន្លែងកើតកូនយ៉ាងតិច ១សប្តាហ៏មុនពេលកើតកូនដើម្បីឱ្យមេស៊ាំនឹងទីកន្លែង
- សម្អាតមេជ្រូកជាមួយសាប៊ូ មុនពេលផ្លាស់ទៅកាន់ទ្រុង ឬកន្លែងកើតកូន
- ទ្រុង ឬកន្លែងកើតកូនត្រូវតែស្អាត និងបាញ់ថ្នាំរម្ងាប់មេរោគ។
- ចាំបាច់ ត្រូវមានទ្រុងសម្រាប់បង្កើតកូន

# ២.កូនជ្រូកច្រើនកើតរស់

## ២.១ ការរៀបចំបង្កើតកូនបានល្អ

- មេជ្រូក ១អាទិត្យមុនពេលកើតកូនៈ មេជ្រូកក្នុងស្ថានភាពល្អ ទ្រុងស្ងាត់ស្ងៀម ស្អាត និងមានអនាម័យ



# ២.កូនជ្រូកច្រើនកើតរស់

## ២.១ ការរៀបចំបង្កើតកូនបានល្អ

- **ការផ្តល់ចំណី**

មិនចាំបាច់ បញ្ឈប់ការផ្តល់ចំណីទៅមេជ្រូកមុនពេលកើត។ បន្ថយការផ្តល់ចំណី មុនពេលកើតកូន ២ថ្ងៃ ប៉ុន្តែ មិនត្រូវបន្ថយមុនរយៈពេលនេះទេ ព្រោះអាចឱ្យមេជ្រូកក្តៀន។

- **ការផ្តល់ទឹក**

ត្រូវច្បាស់ថា មេជ្រូកអាចផឹកទឹកគ្រប់គ្រាន់។ ថ្ងៃចុងក្រោយមុនពេលកើតកូន មេជ្រូកអស់កម្លាំង និងជូនកាលខ្ជិលឈរផឹកទឹក ហើយត្រូវជួយវាឱ្យផឹកទឹកយ៉ាងតិច ៣០-៣៥ លីត្រក្នុង១ថ្ងៃ។

- **ការឈរ**

ដើម្បីការពារក្តៀន រលាកប្លោកនោម រលាកស្បែក.....មេជ្រូកត្រូវឈរ ៤-៥ដងក្នុង ១ថ្ងៃ ហើយប្រសិន ចាំបាច់ត្រូវជួយវា។

# ២.កូនជ្រូកច្រើនកើតរស់

## ២.១ ការរៀបចំបង្កើតកូនបានល្អ

ទឹកគ្រប់គ្រាន់



ចំណីគ្រប់គ្រាន់



# ២.កូនជ្រូកច្រើនកើតរស់

## ២.១ ការរៀបចំបង្កើតកូនបានល្អ

### បញ្ហាដែលសត្វជួបប្រទះ ដូចជាក្តៅខ្លួន និងមិនស៊ីចំណី

- ពិនិត្យសីតុណ្ហភាពមេជ្រូក នៅពេលព្រឹក(គឺ៣៩អង្សាសេ) ។ ប្រសិនបើសីតុណ្ហភាពខ្ពស់ជាងនេះ ត្រូវពិនិត្យៈ

១- មើលថ្ងៃកើត ដើម្បីប្រាកដថាមេជ្រូកកើតកូនមិនយឺត

២- មើលថាតើមេជ្រូកមានហូរខ្ទុះចេញតាមយោនី ព្រោះអាចមានកូនជ្រូកខ្លះងាប់ក្នុងពោះ

៣-មើលលើការផឹកទឹករបស់មេជ្រូក ប្រសិនវាផឹកមិនបានគ្រប់គ្រាន់ វានឹងការរលាកប្លោកនោម ។

យកល្អត្រូវចាក់អង់ទិប៊ីយ៉ូទិច (ទ្រីមេតូព្រីម-ស៊ុលហ្វា)រយៈពេល ៣-៥ថ្ងៃ ដើម្បីការពារបញ្ហាធ្ងន់ធ្ងរ ។

- ប្រសិនបើរងចាំរហូតដល់ ១១៦ថ្ងៃហើយ ជ្រូកនៅតែមិនកើតកូនទៀត (ត្រូវប្រាកដថារាប់ចំនួនថ្ងៃបានត្រឹមត្រូវ) ត្រូវចាក់ PGF (ប្រូស្តាគ្លង់ឌីនមានដូចជា ស៊ុយប្រូស ឬដីណូលីទិច) ជួយបើកកស្បូន និងជំរុញឱ្យកើតកូន ក្នុងរយៈពេល ១២ម៉ោងបន្ទាប់ ។

# ២.កូនជ្រូកច្រើនកើតរស់

## ២.១ ការរៀបចំបង្កើតកូនបានល្អ

ពិនិត្យសីតុណ្ហភាពមុនពេលកើតកូន



- ប្រសិនកើតកូនយឺត ចាក់ថ្នាំបើកស្បូន



# ២.កូនជ្រូកច្រើនកើតរស់

## ២.២  កំណត់សញ្ញាបង្ហាញពីការកើតកូន

១០  ថ្ងៃមុនកើតៈ  ក្រពេញដោះរីកធំ  ហើយរឹង



# ២.កូនជ្រូកច្រើនកើតរស់

## ២.២ កំណត់សញ្ញាបង្ហាញពីការកើតកូន

១០ ថ្ងៃមុនកើត: តែមយោនីឡើងហើម

- យោនីធម្មតា



- យោនី ១០ថ្ងៃមុនពេលកើត



# ២.កូនជ្រូកច្រើនកើតរស់

## ២.២ កំណត់សញ្ញាបង្ហាញពីការកើតកូន

### ៨-១២ ម៉ោងមុនពេលកើត៖ ចេញទឹកដោះ



# ២.កូនជ្រូកច្រើនកើតរស់

## ២.២ កំណត់សញ្ញាបង្ហាញពីការកើតកូន

- ៣០ ទៅ៩០នាទីមុនពេលកើតកូនៈ មានហូរចេញទឹកភ្លោះ



# ២.កូនជ្រូកច្រើនកើតរស់

## ២.៣ ការកើតកូនធម្មតា

៣០ ទៅ៩០នាទីបន្ទាប់ពីហូរចេញទឹកភ្លោះ

- កូនជ្រូកទី១កើត
- កូនជ្រូកកើតបន្តបន្ទាប់គ្នាពីកូនជ្រូក១ ទៅមួយទៀតក្នុងរយៈពេល ១៥នាទី ហើយយូរបំផុត ៣០នាទី ។
- រយៈពេលសរុបនៃការកើតកូនប្រែប្រួល អាស្រ័យចំនួនកូនក្នុង ១សំបុក ប៉ុន្តែជាធម្មតាការកើតកូន មានរយៈពេលតិចជាង ២ម៉ោងកន្លះ ។
- ជាទូទៅ សុកធ្លាក់ ២-៤ម៉ោងបន្ទាប់ពីកូនជ្រូកចុងក្រោយកើតរួច
- នៅពេលកើតរួចរាល់ហើយ ត្រូវចាក់អុកស៊ីតុកស៊ីន ២សេសេតាមសាច់ដុំដើម្បីទម្លាក់សុក

# ២.កូនជ្រូកច្រើនកើតរស់

## ២.៣ ការកើតកូនធម្មតា

- កូនជ្រូកកើតដំបូង



# ២.កូនជ្រូកច្រើនកើតរស់

## ២.៣ ការកើតកូនធម្មតា



# ២.កូនជ្រូកច្រើនកើតរស់

## ២.៣ ការកើតកូនធម្មតា



# ២.កូនជ្រូកច្រើនកើតរស់

## ២.៣ ការកើតកូនធម្មតា





# ២.កូនជ្រូកច្រើនកើតរស់

## ២.៣ ការកើតកូនធម្មតា

- កូនជ្រូកកើតដោយចេញកន្ទុយមកមុន



# ២.កូនជ្រូកច្រើនកើតរស់
## ២.៣ ការកើតកូនធម្មតា

- កូនជ្រូកទី២កើត១៥នាទីក្រោយ



- កូនជ្រូកកើតបន្តទៀត



# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត
## ២.៣ ការកើតកូនធម្មតា

- សុកធ្លាក់



- ចាក់អុកស៊ីតូកស៊ីន



# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៤ ការជួយបង្កើតកូន

### កំណត់បញ្ហាមុនពេលកើត

- ផើមលើសដល់ ១១៦ថ្ងៃ (ការផើមធម្មតាមានរយៈពេល ១១៤ថ្ងៃ)
- មេជ្រូកមិនស៊ីចំណី ហើយឡើងកំដៅ (ធម្មតាមេជ្រូកមិនស៊ីចំណីមួយថ្ងៃមុនការកើត ហើយកំដៅក្នុងខ្លួនមេជ្រូកពេលព្រឹក ៣៨,៥ អង្សារសេ)
- ទឹកភ្លោះ មានក្លិនស្អុយ
- ភ្នែកមេជ្រូកឡើងក្រហម

បញ្ហានេះ អាចបណ្ដាលមកពីកូនជ្រូកងាប់ ឬកើតមិនរួច និងការចាប់ផ្ដើមឆ្លងមេរោគ។

ប្រសិនបើមេជ្រូកមានកំដៅ ៤១អង្សាសេ មិនស៊ីចំណីក្នុងរយៈពេល ២-៣ថ្ងៃ និងទឹកភ្លោះមានក្លិនស្អុយៈ

- ត្រូវចាក់ប្រូស្តាគ្លង់ឌីន (Prostaglandin) ដូចជាស៊ុយប្រូស (Suiprost) ឬ ដីណូលីទិច (Dinolytic) ធ្វើឱ្យកូនកើត
- ត្រូវចាក់អង់ទិប៊ីយ៉ូទិច ដូចជា អង់រ៉ូហ្លុកសាស៊ីន (Enrofloxacine) ឬតេត្រាស៊ីគ្លីន (Tetracycline)
- នៅពេលកស្បូនបើក លូកដៃទាញកូនជ្រូកងាប់

# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៤  ការជួយបង្កើតកូន

- ទឹករំអិលឈាមមិនប្រក្រតី



- កូនជ្រូកកើតងាប់



# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត
# ២.៤  ការជួយបង្កើតកូន

## កំណត់បញ្ហាពេលកើត

- ចន្លោះពេលកើតកូនពីមួយទៅមួយលើស ៤០នាទី ហើយមេជ្រូកនៅតែមានពោះធំ
- អស់កម្លាំងបន្ទាប់ពីវាប្រឹងកើតកូនយូរខុសធម្មតា
- មេជ្រូកមុខស្រពោន ហើយដកដង្ហើមញាប់, ខ្សោយ
- ភ្នែកឡើងក្រហម

បញ្ហានេះ អាចបណ្តាលមកពី:

- ស្បូនមិនកន្ត្រាក់: ចាក់អុកស៊ីតុកស៊ីន  ១សេសេ ហើយរង់ចាំ ១០នាទី
- ទីតាំងរបស់កូនជ្រូកខុសធម្មតា: ត្រូវលូកដៃទាញបង្វិលកូនជ្រូកឱ្យចំទីតាំងវិញ
- កូនជ្រូកធំ: ជួយទាញកូនជ្រូក (ចំណាំ: គ្មៀន ឬប្លោកនោមពេញដោយទឹកនោម ពិបាកក្នុងការទាញកូន)

# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៤ ការជួយបង្កើតកូន

### វិធីជួយសង្គ្រោះ

- សម្អាតយោនី និងរន្ធគូថ
- ត្រូវកាត់ក្រចកដៃឱ្យខ្លី
- លាងដៃជាមួយនឹងសាប៊ូ និងលាបប្រេងរំអិល ( ប្រេងឆា)
- ប្រអប់ដៃដែលលូកចូលត្រូវមានរាងស្រួចដូចសាជី
- ត្រូវលូកដៃចូលថ្នមៗតាមផ្លូវបន្តពូជ
- លូកដៃឆ្លងកាត់ឆ្អឹងត្រគាករហូតដល់ស្បូន
- កំណត់បុព្វហេតុដែលបង្កឱ្យមានបញ្ហាៈ

១- ទីតាំងកូនខុសធម្មតា

២- កូនជ្រូកធំពេក

***ត្រូវប្រុងប្រយ័ត្នកុំឱ្យដាច់ភ្នាសស្បូន ឬសរសៃឈាមក្នុងយោនី***

ប្រសិនបើយើងលូកដៃចូលក្នុងស្បូនមេជ្រូក ចាក់អង់ទីប៊ីយ៉ូទិច យ៉ាងតិច ៣ថ្ងៃ

***-ចំណាំ:*** មុនលូក ត្រូវច្បាស់ថាដៃរបស់យើងគ្មានដំបៅ ។

# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៤ ការជួយបង្កើតកូន



# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៤ ការជួយបង្កើតកូន

- ស្ទះត្រង់ស្មា: ទាញជើងឱ្យត្រង់ទៅមុខ ដោយមិនឱ្យដាច់ស្បូនឡើយ
- គូថចេញមុន: យកខ្សែថ្លក់គន្លាក់ជើងខាងក្រោយ ដោយប្រើចង្អុលដៃ ហើយទាញជើងឱ្យត្រង់





# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៤ ការជួយបង្កើតកូន

កូនជ្រូកធំពេក

- លូកដៃចាប់ទាញក្បាល



កូនជ្រូកធំពេក

- ប្រើខ្សែទាក់ក



# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៤ ការជួយបង្កើតកូន

- សុកមិនធ្លាក់

ប្រសិនបើ ២-៣ម៉ោងក្រោយពេលការកើតកូនរួចរាល់ហើយ សុកនៅតែមិនធ្លាក់ ចាក់អុកស៊ីតុកស៊ីន ២សេសេ

<u>វិធីដឹងថា កូនជ្រូកកើតអស់៖</u>

- មេជ្រូកនៅស្ងៀម
- មេជ្រូកមិនប្រឹងកើត/កន្ត្រាក់
- កូនជ្រូកចាប់ផ្តើមរត់រកមេ
- មេជ្រូកឧស្សាហ៍ក្រោកឈរ និងផឹកទឹក

***ជាការល្អ ត្រូវចាក់អុកស៊ីតុកស៊ីន ២សេសេ នៅពេលវាកើតកូនអស់ ដើម្បីជួយសម្អាតស្បូន***

# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៤ ការជួយបង្កើតកូន

ស្រុតស្បូនៈ ជួនកាល បន្ទាប់ពីកើតកូនរួច មេជ្រូកកន្ត្រាក់រុញស្បូនចេញក្រៅៈ

- ចាក់អាណាហ្សាំង (Analgine) ឬកាម៉ាស៊ីន (Calmagine) ដើម្បីបន្ថយការកន្ត្រាក់
- សម្អាតវា ជាមួយទឹកក្ដៅអ៊ុនៗ
- រុញស្បូនចូលក្នុងវិញយឺតៗ និងដោយប្រុងប្រយត្ន័
- ដេរយោនីជាមួយខ្សែអំបោះមិនរលាយ
- ចាក់អង់ទីប៊ីយ៉ូទិច ( ទ្រីមេតូព្រីម (Trimetoprim) ជាមួយស៊ុលហ្វា (Sulfa) )
- កាត់អំបោះចេញ ៣ថ្ងៃបន្ទាប់



# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៥ ការជួយកូនជ្រូកដែលទើបកើត

- នៅពេលកូនជ្រូកកើត ត្រូវសម្អាតទឹករំអិលពីរន្ធច្រមុះ និងមាត់ ដើម្បីឱ្យវាដកដង្ហើមស្រួល។ ជូតសម្អាតកូនជ្រូកឱ្យស្ងួត។



# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៥ ការជួយកូនជ្រូកដែលទើបកើត

កូនជ្រូករុំក្នុងសុក

- ជួនកាល កូនជ្រូកចុងក្រោយត្រូវរុំជាប់ក្នុងសុក។ កូនជ្រូកនេះ នឹងថប់ដង្ហើម។
- ត្រូវជួយជាបន្ទាន់ យកសុកចេញពីជុំវិញកូនជ្រូក និងជួយឱ្យកូនជ្រូកដកដង្ហើម



# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៥ ការជួយកូនជ្រូកដែលទើបកើត

### ការពិនិត្យទងផ្ចិត

- ជាញឹកញាប់ ទងផ្ចិតនៅតែជាប់ជាមួយនឹងមេជ្រូកជាច្រើននាទី។ ប្រសិនបើវាមិនដាច់ដោយខ្លួនឯងទេ យើងត្រូវទាញរហូតដល់វាដាច់ចេញពីមេ។
- កូនជ្រូកជួនកាលកើតមកមានហូរឈាម ឬកកឈាមនៅទងផ្ចិតដោយខ្លួនឯង។
- ជួនកាល យើងប្រឈមមុខនឹងការហូរឈាមមិនដាច់ពីផ្ចិតក្នុងកំឡុងពេល ៣ ទៅ៤ម៉ោងបន្ទាប់ពីកើត។
- ត្រូវជ្រលក់ទងផ្ចិត ជាមួយទឹកអ៊ីយ៉ូដីន
- ប្រសិនមានឈាមហូរ ត្រូវចងទងផ្ចិតបន្ទាប់ពីសម្លាប់មេរោគជាមួយទឹកអ៊ីយ៉ូដីនរួច

# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៥ ការជួយកូនជ្រូកដែលទើបកើត

- ការជ្រលក់ទងផ្ចិតក្នុងទឹកអ៊ីយ៉ូតឌីន



- ការចងទងផ្ចិត



# ២.កូនជ្រូកច្រើនរស់ក្រោយពេលកើត

## ២.៥  ការជួយកូនជ្រូកដែលទើបកើត

### ការពារការសង្កត់កូនទើបកើត

- ក្នុងកំឡុងពេលកើតកូនមេជ្រូក តែងតែក្រោកឈរ ដូចនេះត្រូវឱ្យកូនជ្រូកនៅឆ្ងាយពីមេជ្រូក ដើម្បីការពារការសង្កត់។ មេជ្រូកងាយនឹងសង្កត់កូន ទើបនឹងកើត។
- ការពារកូនជ្រូកទើបកើតកុំឱ្យងាប់ ចាំបាច់ណាស់ ត្រូវមើលការខុសត្រូវពេលកើត និង ជាពិសេស២-៣ ម៉ោងបន្ទាប់ពីកើត។



ង រឹងមាំ

# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.១ សារៈសំខាន់នៃរយៈពេល ៣ថ្ងៃដំបូង

- ៣ ថ្ងៃដំបូងមានសារៈសំខាន់ណាស់ក្នុងការគ្រប់គ្រងកូនជ្រូក ព្រោះជាង ៥០ភាគរយនៃកូនជ្រូកងាប់កើតមានឡើងក្នុងរយៈពេល ៣ថ្ងៃនេះ។ ការគ្រប់គ្រងកូនជ្រូកបានល្អក្នុងកំឡុងពេលនេះ នឹងបង្កើនផលិតកម្មកូនជ្រូក។

- ការថែរក្សាកូនជ្រូកបានត្រឹមត្រូវក្នុងរយៈពេល ៣ថ្ងៃដំបូង នឹងធ្វើឱ្យវាមានសុខភាពល្អ ក្នុងពេលបំបៅ និងការពារ បញ្ហាខ្លះ ក្រោយពេលផ្តាច់ដោះ

  ការបៅទឹកដោះដំបូង ធ្វើឱ្យកូនជ្រូកមានភាពស៊ាំ មានសមត្ថភាពទប់ទល់នឹងមេរោគ នៅពេលផ្តាច់ដោះ។

- ការថែទាំល្អ នឹងធ្វើឱ្យមេជ្រូកសំបូរទឹកដោះ

  ទប់ស្កាត់អត្រាងាប់ ក្នុងរយៈពេល ៣ថ្ងៃដំបូង និងធ្វើឱ្យចំនួនកូនជ្រូករស់ច្រើនក្នុងសំបុក។

  កូនជ្រូកយ៉ាងតិច ៦ក្បាលដែលជាចំនួន ចាំបាច់សម្រាប់ភ្នោចទឹកដោះ

# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.២ ការថែទាំកូនជ្រូកជាពិសេស

ជំរុញការបៅដោះដំបូង

- ទឹកដោះដំបូង (កូឡូសស្រ្តូម) ជាទឹកដោះដែលផលិតដំបូងដោយមេជ្រូក ក្នុងកំឡុងពេល និង១ថ្ងៃក្រោយពេលកើត

  ទឹកដោះដំបូងនេះ សម្បូរដោយថាមពល និងអាចផ្តល់ចំពោះកូនជ្រូកដែលខ្វះក្រោយពេលកើត។ កង្វះថាមពល ធ្វើឱ្យកូនជ្រូកខ្សោយ សីតុណ្ហភាពក្នុងខ្លួនថយចុះ បន្ទាប់មករាគ ហើយស្លាប់។

  ទឹកដោះដំបូងនេះ សម្បូរអង់ទីគ័រ ដែលការពារកូនជ្រូកក្នុងរយៈពេល ១អាទិត្យដំបូង

- ជាការចាំបាច់ ត្រូវពិនិត្យថា មេជ្រូកផលិតទឹកដោះដំបូងគ្រប់គ្រាន់

- ជាការចាំបាច់ ត្រូវជួយកូនជ្រូកដែលខ្សោយ ឱ្យបៅទឹកដោះដំបូងក្រោយពេលវាកើតបាន ១ម៉ោង

# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.២ ការថែទាំកូនជ្រូកជាពិសេស

- កូនជ្រូកព្យាយាមរកក្បាលដោះបៅភ្លាម បន្ទាប់ពីកើត



- ជួយកូនជ្រូកឱ្យបៅដោះ



# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.២ ការថែទាំកូនជ្រូកជាពិសេស

- របៀបល្អ ក្នុងការថែទាំកូនជ្រូកៈ គ្រួសារនេះអង្គុយជិតមេជ្រូក និងជួយកូនជ្រូកឱ្យបៅទឹកដោះដំបូង និងការពារការសង្កត់កូន





# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយះពេល ៣ថ្ងៃ

## ៣.២ ការថែទាំកូនជ្រូកជាពិសេស

ធ្វើឱ្យមានកម្តៅដល់កូនជ្រូកៈ រៀបចំសំបុក

- សំបុក គឺសំខាន់ក្នុងកំឡុងពេលថ្ងៃដំបូងនៃជីវិតៈ

គោលបំណងគឺៈ

- ផ្តល់កន្លែងមានសុវត្ថិភាពសម្រាប់ដេកៈ ជាពិសេសប្រើឡាំង ដើម្បីកុំឱ្យមេកិន។
- ផ្តល់កន្លែងកក់ក្តៅ សម្រាប់ដេក

  - នៅពេលដែលកូនជ្រូករងា សកម្មភាពបញ្ចូនចំណីរបស់ ពោះវៀនមានសភាពយឺត ធ្វើឱ្យមេរោគអ៊ីកូលី រីកលូតលាស់ ហើយធ្វើឱ្យកូនជ្រូករាគ

  - ជៀសវាងកុំឱ្យកូនជ្រូកបាត់បង់ថាមពល និងខ្សោយៈ កូនជ្រូក នឹងប្រើប្រាស់ចំណីដើម្បីរក្សាកំដៅខ្លួន មិនមែនសម្រាប់ការលូតលាស់

សំបុកត្រូវស្ងួត ស្អាត និងកក់ក្តៅៈ កុំប្រើសម្ភារៈកខ្វក់ ក្រណាត់ចាស់ដាក់ជាកំរាលសំបុក ព្រោះ អ៊ីកូលី អាចលូតលាស់ និងរស់រានមានជីវិត។ ត្រូវសម្លាប់មេរោគក្នុងសំបុកជាប្រចាំ។

# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.២ ការថែទាំកូនជ្រូកជាពិសេស

- ការរៀបចំសំបុកតាមទម្លាប់





# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.៣ ការពារ និងព្យាបាលមូលហេតុបណ្តាលឱ្យងាប់

- **រាគ៖** ការរាគ ៣ថ្ងៃដំបូងរបស់កូនជ្រូក បណ្តាលឱ្យវាខ្វះជាតិទឹក និងងាប់ ដូច្នេះត្រូវព្យាបាលជាបន្ទាន់






# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.៣ ការពារ និងព្យាបាលមូលហេតុបណ្ដាលឱ្យខាប់

ការពារ និងព្យាបាលរាគៈ

មូលហេតុមួយគឺៈ

- <u>ទឹកដោះមេជ្រូកមានមេរោគ អ៊ីកូលីៈ</u>

ក្តៀនមុនពេលកើត លាសដោះ( ដោះឡើងរឹងក្រហម ហើយឈឺ) កន្លែងរស់នៅកខ្វក់អាចឱ្យទឹកដោះងាយ ឆ្លងអ៊ីកូលី និងធ្វើឱ្យកូនជ្រូករាគខ្លាំង

សំខាន់ត្រូវការពារកុំឱ្យមេជ្រូកក្តៀនៈ ផ្តល់បន្លែបៃតងឱ្យស៊ីមុនពេលកើត

សំខាន់ត្រូវព្យាបាលជំងឺលាសដោះៈ មើលសីតុណ្ហភាពមេជ្រូកមុនពេលកើត ( ៣៨,៥ អង្សាសេ ទៅ ៣៩ អង្សាសេ ពេលព្រឹក) និងពិនិត្យមើលកន្សោមដោះរឹង។ ប្រសិនកម្តៅឡើងខ្ពស់ ហើយកន្សោមដោះរឹង ចាក់ទ្រីមេតូព្រីម (Trimetoprim) +ស៊ុលហ្វា (Sulfa) ។ ប្រការទាំងនេះប្រុងប្រយត្ន័ក្រោយពេលវាកើតកូនរួច។

# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.៣ ការពារ និងព្យាបាលមូលហេតុបណ្តាលឱ្យខាប់

កន្ទៀរាមដោះល្អ ជាមួយកូនជ្រូកមានសុខភាពល្អ



កន្ទៀរាមដោះមិនល្អ



# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.៣ ការពារ និងព្យាបាលមូលហេតុបណ្តាលឱ្យខាប់

### ការពារ និងព្យាបាលរាគៈ

មូលហេតុមួយទៀតគឺៈ

- <u>សីតុណ្ហភាពត្រជាក់ និងក្តៅហួតហែងៈ</u>

ពេលត្រជាក់ ពោះកូនជ្រូកត្រជាក់ ហើយការបញ្ជូនចំណីរបស់ពោះវៀនមានសភាពយឺត។ មេរោគ អ៊ីកូលីមានឱកាសរីកលូតលាស់ និងធ្វើឱ្យកូនជ្រូករាគ។

ចាំបាច់ត្រូវដឹងថាពេលណាកូនជ្រូកត្រជាក់ (កូនជ្រូកផ្តុំគ្នានៅជ្រុងម្ខាងនៃទ្រុង)

ចាំបាច់ត្រូវទ្រុងត្រូវស្ងួត

ចាំបាច់ត្រូវរៀបចំសំបុកដែលមានសីតុណ្ហភាពសមស្រប (៣០ អង្សាសេ) ជាពិសេសនៅពេលយប់

ចាំបាច់ត្រូវការពារទ្រុងកើត (បាំងជញ្ជាំង) កុំឱ្យជះកម្តៅចូលខ្លាំង

# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.៣ ការពារ និងព្យាបាលមូលហេតុបណ្តាលឱ្យទាប់

- កូនជ្រូកត្រជាក់



- កូនជ្រូកមានភាពកក់ក្តៅ



# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.៣ ការពារ និងព្យាបាលមូលហេតុបណ្តាលឱ្យងាប់

### ការពារ និងព្យាបាលរាគៈ

មូលហេតុមួយទៀតគឺៈ

- <u>ការចម្លងដោយកូនជ្រូកឈឺ</u> ដែលរស់នៅទ្រុងជិតខាង ឬដោយមនុស្សដែលមានស្បែកជើងប្រឡាក់លាមករាគ

កូនជ្រូកអាយុ ២អាទិត្យ អាចរាគ ប៉ុន្តែមិនងាប់ទេ។ ប្រសិនបើ ពួកវាទាំងនេះបានប៉ះពាល់ ឬរស់នៅលាយឡំជាមួយកូនជ្រូកថ្មីទើបកើតថ្មី ពួកវានឹងចម្លងទៅកូនជ្រូកទើបកើត ព្រោះកូនជ្រូកទើបកើតមានសភាពខ្សោយជាង។

មនុស្សយើងអាចពាំនាំមេរោគ អ៊ីកូលីតាមស្បែកជើង នៅពេលចូលក្នុងទ្រុងដែលមានជម្ងឺរាគ ហើយបន្ទាប់មកគាត់ចូលទ្រុងផ្សេងទៀតដែលមានកូនជ្រូកទើបកើតថ្មី។

សំខាន់ត្រូវជៀសវាង ដាក់កូនជ្រូកចិញ្ចឹមលាយឡំគ្នា (កូនជ្រូកសំបុក ឬទ្រុងផ្សេងគ្នា)។

កសិករ ឬភ្នាក់ងារសុខភាពសត្វភូមិ ចាំបាច់ត្រូវដោះស្បែកជើងមុនពេលចូលក្នុងទ្រុងកូនជ្រូកទើបកើតថ្មី។

# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.៣ ការពារ និងព្យាបាលមូលហេតុបណ្តាលឱ្យខាប់

- ការពារ និងព្យាបាលរាគៈ
- ត្រូវព្យាបាលជំងឺរាគ ជាបន្ទាន់ៈ បើមិនដូច្នោះទេ ២-៣ម៉ោងក្រោយមក កូនជ្រូករាគនឹងខ្សោះជាតិទឹក ហើយពិបាកជួយសង្គ្រោះ ។
- នៅពេលឃើញ កូនជ្រូក ១ ឬ ២មានជំងឺរាគនៅក្នុងទ្រុង ត្រូវព្យាបាលកូនជ្រូកទាំងអស់ក្នុងសំបុក
- នៅពេលកូនជ្រូកទើបកើត មានជម្ងឺរាគ វាសំខាន់ណាស់ ត្រូវពិនិត្យមេជ្រូក (សីតុណ្ហភាព ស្ថានភាពកន្ទ្រាមដោះ ការផលិតទឹកដោះ......) ជាញឹកញាប់ទឹកដោះ គឺជាមូលហេតុនៃការចម្លងមេរោគ

<u>ការព្យាបាលៈ</u>

- កូនជ្រូកៈ ចាក់អង់ទីប៊ីយ៉ូទិច ប្រឆាំងនឹងមេរោគ អ៊ីកូលី (កូលីស្ទីន (Colistin) គឺជាអង់ទីប៊ីយ៉ូតិចដ៏សំខាន់)

កូលីស្ទីន (Colistin) ជាញឹកញាប់រួមផ្សំជាមួយ ប៉េនីស៊ីលីន (Ampicillin): (ប៊ីយ៉ូកូលីស្ទីន (Biocolistine), អំពីដិចសាឡោន (Ampidexalone) ...) ត្រូវចាក់ពេលព្រឹក និង ល្ងាច រហូតដល់ជាសះស្បើយ ។ ប្រសិនបើអាច ត្រូវបញ្ច្រុក កូលីស្ទីន (Colistin) តាមមាត់ ។

ពិនិត្យកូនជ្រូកថាមិនត្រជាក់

- មេជ្រូកៈ ចាក់ទ្រីមេតូព្រីម (Trimetoprim) +ស៊ុលហ្វា (Sulfa) មួយថ្ងៃម្តង រយៈពេល ៣ថ្ងៃ

# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.៤ ការគ្រប់គ្រងមេជ្រូកបានល្អ

- ធានាការផ្តល់ទឹកដោះ: ការពារ និងព្យាបាលជំងឺរលាកស្បូន រលាកកន្សោមដោះ និងគ្មានទឹកដោះ

ជំងឺរលាកស្បូន រលាកកន្សោមដោះ និងគ្មានទឹកដោះ គឺជាបញ្ហាធ្ងន់ធ្ងរ: បន្ទាប់ពីកើតកូន មេជ្រូកគ្មានទឹកដោះដំបូង គ្មានទឹកដោះ។

កន្សោមដោះឡើងរឹង មេជ្រូកក្តៅខ្លួន នៅពេលច្របាច់កន្សោមដោះ វាគ្មានទឹកដោះ (សូម្បីតែទឹកដោះ ២-៣ ដំណក់ក៏គ្មាន)។

កូនជ្រូកមិនអាចបៅ ធ្វើឱ្យពួកវាបាត់បង់ថាមពលយ៉ាងឆាប់រហ័ស កូនជ្រូកចាប់ផ្តើមរងា ហើយងាប់ក្នុងរយៈពេល ១ ឬ ២ថ្ងៃ។

ការព្យាបាលត្រូវធ្វើឡើងជាបន្ទាន់។ មិនត្រូវបង្អែរបង្អន់ឡើយ!

១. ចាក់ 0.៥ សេសេ អុកស៊ីតុកស៊ីន (Ocytocine) តាមសរសៃឈាម (សរសៃវ៉ែនត្រចៀក) ហើយទឹកដោះចេញ ២-៣ វិនាទីក្រោយ

អ្នកត្រូវដាក់កូនជ្រូក ឱ្យបៅជាបន្ទាន់។ ចាក់ ៣ដងក្នុង ១ថ្ងៃ។

២. ចាក់អង់ទិប៊ីយ៉ូតិច: ទ្រីមេតូព្រីម (Trimetoprim) +ស៊ុលហ្វា (Sulfa) រយៈពេល៥ថ្ងៃ

៣. ចាក់ដិចសាមេតាសូន (Dexamethasone) បើកន្សោមដោះរឹង

៤. ចាក់ថ្នាំបញ្ចុះកម្តៅ បើសីតុណ្ហភាពក្នុងខ្លួនកើនលើសពី ៤0អង្សារសេ

# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.៤ ការគ្រប់គ្រងមេជ្រូកបានល្អ

- ជំងឺរលាកស្បូន រលាកកន្សោមដោះ និងគ្មានទឹកដោះ៖

គ្មានទឹកដោះពេលពិនិត្យមើលកន្សោមដោះ



ការចាក់អុកស៊ីតុកស៊ីនតាមសរសៃឈាម



# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.៤ ការគ្រប់គ្រងមេជ្រូកបានល្អ

- ការពារការសង្កត់កូនដោយមេជ្រូក

ការសង្កត់កូន គឺជាមូលហេតុសំខាន់បង្កឱ្យងាប់នៅថ្ងៃកើតដំបូង ហើយអាចការពារបានៈ

- កើតកូនក្នុងទ្រុងសមរម្យ
- កូនជ្រូកខ្លាំង ប្រសិនបើពួកវាមិនបាត់បង់ថាមពលទេៈ ការពារភាពត្រជាក់ (ត្រូវមានសំបុកត្រឹមត្រូវ) និងឱ្យកូនជ្រូកបៅទឹកដោះដំបូង
- ការពារការទន់ជើងរបស់មេជ្រូកដោយផ្តល់វីតាមីនអ៊ី និងសេលេនីញ៉ូម (Vit E+ Selenium) កំឡុងពេល ៣អាទិត្យមុនពេលកើត
- ព្យាបាលនៅពេលមេជ្រូកមានបញ្ហាជើង ដើម្បីជៀសវាងការដើរមិនរួច

# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.៤ ការគ្រប់គ្រងមេជ្រូកបានល្អ

- ការប្រឈមនឹងការសង្កត់កូន



- ការសង្កត់កូន



# ៣.កូនជ្រូកកាន់តែច្រើនអាចរស់ក្រោយរយៈពេល ៣ថ្ងៃ

## ៣.៤ ការគ្រប់គ្រងមេជ្រូកបានល្អ

ទ្រុងត្រឹមត្រូវ (បែបប្រពៃណី)



ទ្រុងត្រឹមត្រូវ (ទំនើប)



# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលបៅដោះ

## ៤.១ ការគ្រប់គ្រងសុខភាពកូនជ្រូក

- ការកាត់ធ្មេញ

  - ការពារកុំឱ្យមានរបួសពេលកូនជ្រូកខាំគ្នា

  - ការពារការខាំដោះនៅពេលកូនជ្រូកបៅ

សំខាន់ត្រូវយកចិត្តទុកដាក់ពេលកាត់ មិនត្រូវឱ្យប៉ះពាល់អញ្ចាញ

ត្រូវប្រើប្រដាប់កាត់ធ្មេញឱ្យសមស្រប

ត្រូវធ្វើការរម្ងាប់មេរោគលើឧបករណ៍កាត់ធ្មេញ

វាមានសុវត្ថិភាព និងមានប្រសិទ្ធភាព ក្នុងការកាត់ធ្មេញពាក់កណ្ដាល

ការងារនេះ ត្រូវធ្វើមុនពេលកូនជ្រូកអាយុបាន ៣ថ្ងៃ

# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលបៅដោះ

## ៤.១ ការគ្រប់គ្រងសុខភាពកូនជ្រូក

ការរម្ងាប់មេរោគដោយទឹកអ៊ីយ៉ូត




បច្ចេកទេសក្នុងការកាត់ធ្មេញ



# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលបៅដោះ

## ៤.១ ការគ្រប់គ្រងសុខភាពកូនជ្រូក

### ការកាត់កន្ទុយ

- ជួយកាត់បន្ថយការខាំកន្ទុយ និងការឆ្លងមេរោគនៅពេលកូនជ្រូកអាយុច្រើន
- ត្រូវប្រញាប់កាត់កន្ទុយចោល ពាក់កណ្តាល ទៅ ៣/៤ ហើយលាបទឹកអ៊ីយ៉ូដីននៅចុងកន្ទុយនោះ
- រម្ងាប់មេរោគលើកាំបិតវះជាមួយទឹកអ៊ីយ៉ូដីន
- លាបទឹកអ៊ីយ៉ូដីនត្រង់កន្ទុយដែលត្រូវកាត់
- ការកាត់កន្ទុយនេះត្រូវធ្វើ មុនពេលកូនជ្រូកអាយុបាន ៣ថ្ងៃ



# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលបៅដោះ

## ៤.១ ការគ្រប់គ្រងសុខភាពកូនជ្រូក

ការចាក់អាម៉ុកស៊ីលីន (Amoxicilline)

- ផ្ចិត, កន្ទុយកាត់, ធ្មេញកាត់ និងស្លាកស្នាមជង្គង់ គឺជាផ្លូវចម្លងមេរោគ ជាពិសេសពពួកស្រ្តិបតូកូកុស
- ក្រោយពីកើតបាន ២៤ ម៉ោង ត្រូវចាក់អាម៉ុកស៊ីលីនមានសកម្មភាពយូរ (Amoxicilline LA.) ០.៥ សេសេ ជួយកូនជ្រូកប្រឆាំងការឆ្លងមេរោគសម្រាប់ជីវិតថ្មីរបស់ពួកគេ
- ការឆ្លងមេរោគតាមផ្ចិត នឹងធ្វើឱ្យមានបញ្ហាអ៊ែកនីចំពោះកូនជ្រូកក្រោយផ្តាច់ដោះ

ស្លាកស្នាមជង្គង់ (កំរាលមិនសមស្រប)



# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលបៅដោះ

## ៤.១ ការគ្រប់គ្រងសុខភាពកូនជ្រូក

- ការឆ្លងមេរោគតាមផ្ចិត: នឹងធ្វើឱ្យមានបញ្ហាអែកនីចំពោះកូន ជ្រូកក្រោយផ្តាច់ដោះ



# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលបៅដោះ

## ៤.១ ការគ្រប់គ្រងសុខភាពកូនជ្រូក

ការចាក់ជាតិដែក

- ជាតិដែកបំរុង ចំពោះកូនជ្រូកកើតមកភ្លាមមានកំរិត
- ទឹកដោះមិនអាចផ្តល់ ជាតិដែកដល់កូនជ្រូកឱ្យបានគ្រប់គ្រាន់ទេ
- ការខ្វះជាតិដែក ធ្វើឱ្យកូនជ្រូកខ្វះឈាម ដែលបណ្តាលឱ្យកូនជ្រូកមិនសូវស៊ីចំណី និងមិនសូវលូតលាស់
- ជាតិដែកបន្ថែម ត្រូវចាក់នៅសាច់ដុំត្រង់កនៅថ្ងៃទី២ បន្ទាប់វាកើត និងចាក់ម្តងទៀត ៧ទៅ ១០ថ្ងៃបន្ទាប់
- កំរិតប្រើប្រាស់គឺ ១០០មីលីក្រាមសម្រាប់កូនជ្រូកមួយក្បាល។ អាស្រ័យ ទៅតាមកំរិតនៃការប្រើថ្នាំ ជាទូទៅគេប្រើ ១សេសេ



# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលផ្តាច់ដោះ

## ៤.១ ការគ្រប់គ្រងសុខភាពកូនជ្រូក

### កុកស៊ីដ្យូស៊ីស

- កុកស៊ីដ្យូស៊ីស បង្កឱ្យកូនជ្រូករាគនៅអាយុ ៧ ទៅ ១៥ថ្ងៃ
- ការរាគនេះ មានលក្ខណៈធម្មតា ប៉ុន្តែវាពិបាកព្យាបាលណាស់
- វាមិនបង្កឱ្យស្លាប់ ប៉ុន្តែវាធ្វើកូនជ្រូកចុះទម្ងន់ពេលផ្តាច់ដោះ និងមានទ្រង់ទ្រាយមិនល្អ។
- ការការពារមានប្រសិទ្ធភាពគឺផ្តល់ តុលត្រាស៊ូរីល Toltrazuril (អង់ទិកុក (Anticoc) ឬបេកុក (Baycox) ) ១សេសេ
- ការព្យាបាល គឺជាការការពារតែមួយគត់ និងត្រូវធ្វើ ៣ថ្ងៃបន្ទាប់ពីកើត



# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលបៅដោះ

## ៤.១  ការគ្រប់គ្រងសុខភាពកូនជ្រូក

### ការអនុវត្តន៏ដ៏ល្អសម្រាប់ការក្រៀវ

- ការក្រៀវដែលល្អ ត្រូវធ្វើនៅពេលកូនជ្រូកបានអាយុប្រហែល ៧-១០ថ្ងៃ។
- មុនពេលក្រៀវ ត្រូវច្បាស់ថា កូនជ្រូកគ្មានអ៊ែកនី (ការហើមខុសប្រក្រតីនៃពងស្វាស)។ ប្រសិនបើអ្នកសង្ស័យថាជ្រូកមានអ៊ែកនី កុំក្រៀវវា។
- ប្រើកាំបិតក្រៀវស្រួច(មុត) ធ្វើការវះបញ្ឈរលើស្បែកពងស្វាសត្រង់ចំណុចកណ្តាល (វះម្ខាងម្តង)។ ច្របាច់ពងស្វាសឱ្យចេញក្រៅ រួចកាត់បំពង់តភ្ជាប់មកពងស្វាស។ កាត់បំពង់តភ្ជាប់មកពងស្វាសឱ្យខ្លី។
- បាញ់លាងទឹកអ៊ីយ៉ូតក្នុងរន្ធនោះ
- ការក្រៀវភ្លាម អាចធ្វើឱ្យកូនជ្រូកហើម ២-៣ថ្ងៃ ហើយស្រកមកវិញ

# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលផ្តាច់ដោះ

## ៤.១ ការគ្រប់គ្រងសុខភាពកូនជ្រូក

- ពងស្វាសធម្មតា



- ពងស្វាសដែលកើតអ៊ែរកនី



# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលផ្តាច់ដោះ

## ៤.១ ការគ្រប់គ្រងសុខភាពកូនជ្រូក

- លាងសម្អាតមេរោគកាំបិតវះជាមួយទឹកអ៊ីយ៉ូតដីន
- ការក្រៀវ






# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលបៅដោះ

## ៤.១ ការគ្រប់គ្រងសុខភាពកូនជ្រូក

- សំលាកធម្មតា



- សំលាកឆ្លងមេរោគ



# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលផ្ដោះ

## ៤.២ ការព្យាបាលជម្ងឺធូន់ធូរ

- ជម្ងឺធូន់ធូរ គឺជាជម្ងឺធ្វើឱ្យកូនជ្រូកងាប់ ក្នុងរយ:ពេល ២-៣ម៉ោង
- នៅពេលវាងាប់លឿន យើងមិនអាចឃើញរោគសញ្ញា និងមិនអាចឃើញស្លាកស្នាមនៅពេលយើងធ្វើការវះកាត់
- វាពិបាកក្នុងការព្យាបាលណាស់ដោយសារ នៅពេលកូនជ្រូកចាប់ផ្តើមឈឺ ពួកវាងាប់ភ្លាម ហើយអង់ទីប៊ីយ៉ូទិចគ្មានប្រសិទ្ធភាពទេ។
- វាចាំបាច់ណាស់ ក្នុងការពិនិត្យកូនជ្រូកដទៃទៀតក្នុងសំបុក ដើម្បីកំណត់រោគសញ្ញា (រាគ, ឈឺសន្លាក់ដៃ ជើង, ពិបាកដកដង្ហើម....) ហើយជ្រើសរើសការព្យាបាល
- ចាក់ថ្នាំឱ្យគ្រប់កូនជ្រូក ព្រោះជម្ងឺទាំងនេះ អាចសាយភាយលឿនពីកូនជ្រូកមួយ ទៅកូនជ្រូកមួយទៀត

ការការពារដ៏ល្អបំផុត គឺត្រូតពិនិត្យថាកូនជ្រូកបានបៅទឹកដោះដំបូងច្រើន។ ទឹកដោះដំបូងអាចការពារកូនជ្រូកប្រឆាំងនឹងជម្ងឺ។

# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលបៅដោះ

## ៤.២ ការព្យាបាលជម្ងឺឆ្វន់ឆ្វរ

ជម្ងឺបង្កឡើងដោយពួកស្រ្តិបតូកុកកុស

- កូនជ្រូកខ្លះ ងាប់ភ្លាមដោយមិនបង្ហាញរោគសញ្ញា
- កូនជ្រូកខ្លះទៀត ពិការជើង ( មួយ ឬជើងច្រើន) ដោយមានហើមសន្លាក់

ការការពារ( បង្ការ) :

- ពិនិត្យលើការហើមសន្លាក់របស់កូនជ្រូក ហើយដុសលាងក្បាលជង្គង់ ជើង ឬកន្ទុយ ។
- ពិនិត្យមាត់កូនជ្រូក ដើម្បីឱ្យឃើញថាពួកវាគ្មានដំបៅ ក្រោយពីការកាត់ធ្មេញ
- ចាក់ 0.៥ សេសេអាម៉ុកស៊ីលីនមានសកម្មភាពយូរ ២៤ម៉ោងបន្ទាប់ពីកើត

ការព្យាបាលៈ

- ប្រើអាម៉ុកស៊ីលីនរយៈពេល ៥ថ្ងៃ លាយជាមួយឡាំងកូមីស៊ីន ប្រសិនជាមានការហើមសន្លាក់ខ្លាំង
- ត័រទីសូន ឬថ្នាំប្រឆាំងការរលាកផ្សេងទៀត (ដូចជាតុលហ្វេឌីន (Tolfedine) ) អាចមានប្រសិទ្ធភាព។ ប្រុងប្រយត្ន័ លើកិរិតប្រើប្រាស់ ។ ថ្នាំទាំងនេះ ចាក់តែម្តង ។

# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលបៅដោះ

## ៤.២ ការព្យាបាលជម្ងឺធ្ងន់ធ្ងរ

**ការរាគ**

មេរោគសំខាន់ដែលធ្វើឱ្យរាគ គឺពួក អ៊ីកូលី និងក្លូសទ្រីឌ្យ៉ា ( ប្រសិនបើរាគឈាម)

ការរាគកើតមានលើកូនជ្រូក កំពុងបៅដោះគ្រប់អាយុ តែវាមានចន្លោះពេលពីរសំខាន់ គឺមុនពេលកូនជ្រូក អាយុ៥ថ្ងៃ ( គុណភាពទឹកដោះអន់ កូនជ្រូករងា) និងនៅចន្លោះអាយុពី ៧ ទៅ១៤ថ្ងៃ ( កូនជ្រូកមិនបានការពារដោយទឹកដោះដំបូងទៀតទេ) ។

រោគសញ្ញាតែមួយគត់ដែលមើលឃើញ គឺកូនជ្រូកងាប់ ស្បែកនៅជុំវិញរន្ធគូថ និងកន្ទុយសើម ។ មើលជុំវិញទ្រុង ដើម្បីមើលសភាពនៃការរាគ

ការព្យាបាល:

ចាក់អង់ទីប៊ីយ៉ូទិច: កូលីស្ទីន (Colistin) + អំពីស៊ីលីន (Ampicillin) ចាក់ ២ដងក្នុង ១ថ្ងៃរហូតដល់ជា

ចាក់ជាបន្ទាន់ ក្រោយឃើញរាគ ចាក់គ្រប់កូនជ្រូកក្នុងទ្រុង លាងសម្អាតទ្រុង និងទុកកូនជ្រូកនៅកន្លែងកក់ក្ដៅ

ព្យាបាលមេជ្រូក ប្រសិនបើចាំបាច់: ទ្រីមេតូព្រីម (Trimetoprim) + ស៊ុលហ្វា (Sulfa) រយៈពេល ៣ថ្ងៃ

# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលផ្តាច់ដោះ

## ៤.២ ការព្យាបាលជម្ងឺធ្ងន់ធ្ងរ

ជម្ងឺផ្លូវដង្ហើម/ ក្អក

អាទីបាក់ស៊ីឡូស (Actinobacillus) , ជម្ងឺគ្លាសេ (Glasser)

- ការងាប់ភ្លាម បើទោះជាជ្រូកមើលទៅមានសុខភាពល្អក៏ដោយ រួមមានការងាប់ ១ឬ ២ សំបុក និង ១ ឬ២ក្បាលក្នុង១ សំបុក ។ ក្នុងករណីមិនធ្ងន់ធ្ងរ ជ្រូកគ្រុនក្តៅខ្លាំង ក្អក និងរលាកសួត (ពិបាកដកដង្ហើម)

ការព្យាបាលៈ

ត្រូវចាប់ផ្តើមព្យាបាលជាបន្ទាន់

ចាក់ថ្នាំឱ្យកូនជ្រូកទាំងអស់ ព្រោះជម្ងឺផ្លូវដង្ហើម អាចសាយភាយយ៉ាងងាយស្រួលពីកូនជ្រូកមួយទៅកូនជ្រូកមួយទៀត

ចាក់អង់ទិប៊ីយ៉ូតិចៈ អង់រូហ្លុកសាស៊ីន (Enrofloxacine), ហ្លរហ្វេនីកុល (Florfenicol), ស្យាមផេនីកុល (Thiamfenicol) + តេត្រាស៊ីគ្លីន (Tetracycline)

សម្រាប់ជម្ងឺផ្លូវដង្ហើម ចាក់កម្រិតទ្វេរដងនៅថ្ងៃទី១

# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលចៅដោះ

## ៤.៣ ការប្រឈមមុខនឹងការស្លាប់មេជ្រូកពេលបំបៅដោះ

### តើត្រូវជួយកូនជ្រូកដូចម្តេច នៅពេលមេជ្រូកស្លាប់?

- ប្រសិនបើកូនជ្រូក បានបៅទឹកដោះដំបូងហើយ ឱកាសរស់មានខ្ពស់ ព្រោះទឹកដោះដំបូងជួយការពារកូនជ្រូកប្រឆាំងនឹងមេរោគ ។
- រក្សាកូនជ្រូកឱ្យកក់ក្តៅៈ មេជ្រូកគឺជាប្រភពនៃភាពកក់ក្តៅចំពោះកូន ព្យាយាមរក្សាកម្តៅពី ២៧ ទៅ៣០ អង្សារ ។
- ផ្តល់ចំណីឱ្យកូនជ្រូកៈ អ្នកអាចប្រើទឹកដោះគោជំនួស ប៉ុន្តែប្រសិនបើគ្មានទឹកដោះគោទេ អាចរៀបចំៈ ២០០មីលីលីត្រ ទឹកដោះគោខាប់ ៤០០មីលីលីត្រ ទឹក ស៊ុតលឿង១ និងប្រេងឆាកន្លះស្លាបព្រាបាយ

  កម្តៅទឹកដោះគោឱ្យមានសីតុណ្ហភាព ស្មើនឹងសីតុណ្ហភាពដងខ្លួន (ថ្ងៃដំបូង) និងផ្តល់ឱ្យកូនជ្រូករៀងរាល់ ៣-៤ ម៉ោងជាមួយសឺរ៉ាំង

  ២-៣ ថ្ងៃបន្ទាប់ កូនជ្រូកអាចផឹកនឹងកូនចាន នៅពេលកូនជ្រូកបានអាយុ ១០-១២ថ្ងៃ ត្រូវចាប់ផ្តើមឱ្យចំណីរឹងវា

  ទឹកដោះគោ មិនល្អសម្រាប់កូនជ្រូកកើតភ្លាមទេ ព្រោះវាពិបាករំលាយ

# ៤.ការកាត់បន្ថយអត្រាស្លាប់កំឡុងពេលផៅដោះ

## ៤.៣ ការប្រឈមមុខនឹងការស្លាប់មេជ្រូកពេលបំបៅដោះ

- ផ្តល់ចំណីតាមសឺរ៉ាំង



- បង្ហាត់ឱ្យផឹកក្នុងចាន



# ៤. ការបាត់បង់កូនជ្រូកកាន់តែតិចនៅកំឡុងពេលឆ្លងទន្លេ

## ៤.៣ ការប្រឈមមុខនឹងការស្លាប់មេជ្រូកពេលបំពោះ

ការហូរឈាម

- មេជ្រូកអាចស្លាប់បាននៅពេលកើតកូនខណៈពេលដែលមានការហូរឈាមចេញពីសសៃឈាមនៅក្នុងស្បូន។ ការលេចឡើងនៅរោគសញ្ញាខ្វះឈាម (ស្បែក អញ្ចាញ និង ត្របកភ្នែកឡើងស្លេក) វាសបញ្ជាក់ថាវាមានការហូរឈាមនៅខាងក្នុង។ ទោះបីជាយ៉ាងណាក៏ដោយការហូរឈាមនេះអាចនឹងមិនបង្ហាញអោយឃើញមុនពេលដែលមេជ្រូកងាប់ទេ។
- ការបង្ការ

ត្រូវមានការប្រុងប្រយត្ន័ពេលដែលយើងលូកដៃចូលទៅក្នុងស្បូនដោយប្រើដៃនោះត្រូវកាត់ក្រចកដៃ និង ប្រើប្រេង ហើយទាញកូនជ្រូកចេញដោយថ្នមៗ។

# ៤. ការបាត់បង់កូនជ្រូកកាន់តែតិចនៅកំឡុងពេលផ្ដាច់ដោះ

## ៤.៣ ការប្រឈមមុខនឹងការស្លាប់មេជ្រូកពេលបំបៅដោះ

ការត្រកួញពោះវៀន និង ក្រពះ

- ការរមួលរបស់ក្រពះ ឬ ពោះវៀនតូចវាគឺជាបញ្ហាចំបងមួយដែលបណ្តាលអោយមានការស្លាប់នៅពេលពេញវ័យ។
- បរិមាណចំណីយ៉ាងច្រើនដែលបានស៊ីនៅពេលបំបៅដោះ នឹងត្រូវបានរៀបចំទុកជាមុន។
- ការបង្ហាញសញ្ញាភ្លាមៗដែលរួមមានការហើមពោះ ប៉ុន្តែជាទូទៅគេឃើញមេជ្រូកបានស្លាប់ទើបដឹងថាពោះវៀន ឬក្រពះរបស់វាត្រកួញចូលគ្នា។
- ការស្លាប់បណ្តាលពីក្រពះឡើងរឹងហើយរមួលដែលកើតមានជាទូទៅនៅពេលដែលសត្វបានស៊ីចំនីបាន ២-៣ម៉ោងមក។
- ការការពារ: អោយជ្រូកស៊ីពាដងក្នុងមួយថ្ងៃ ជាលទ្ធផលបង្ហាញថាវាមានការប្រឈមមុខនឹងគ្រោះថ្នាក់ដល់ស្លាប់ទាបជាងការអោយជ្រូកស៊ី ២ដង ក្នុងមួយថ្ងៃ។
- ជាការពិត វាគ្មានថ្នាំព្យាបាលវាទេ។

# ៤. កាត់បន្ថយអត្រាស្លាប់ពេលឆ្លងទន្លេ

## ៤.១. បញ្ហាការស្លាប់របស់មេជ្រូក

សុក ឬ កូនជ្រូកងាប់មិនធ្លាក់មកក្រៅ

- ការមិនធ្លាក់ចេញមកក្រៅរបស់សុក ឬ កូនជ្រូកដែលងាប់អាចបណ្ដាលអោយមានភាពស្មុគស្មាញខ្លាំង ដោយធ្វើអោយជ្រូកងាប់ ឬ បញ្ហាផ្សេងទៀត។
- ពេលខ្លះសុកធ្លាក់នៅកំឡុងពេលកើតកូន ប៉ុន្តែភាគច្រើនវានឹងធ្លាក់បន្ទាប់ពីការកើតកូនរួច ឬ ២-៣ ម៉ោងក្រោយមកទៀត។
- ពេលខ្លះវាជាការលំបាកសំរាប់និយាយថាសុកបានធ្លាក់អស់ហើយ ឬនៅសល់។

# ៤. កាត់បន្ថយអត្រាស្លាប់ពេលផ្តាច់ដោះ

## ៤.១. បង្ការការស្លាប់របស់មេជ្រូក

<u>ការបង្ការ</u>

- ច្បាស់ថាជ្រូកពិតជាបានធ្លាក់សុកមកក្រៅហើយ ។ អ្នកត្រូវតែឃើញវា ។
- ចាក់អុកស៊ីតុកស៊ីន ២ សេសេនៅពេលដែលការការកើតកូនបានបញ្ចប់ ។

<u>ការព្យាបាល</u>

- ជ្រូកមិនស៊ីចំណី ក្តៅលើសពី ៤0អង្សា ពេលខ្លះយើងអាចឃើញមានការហូរចេញនូវសារធាតុខ្ទុះក្លិនស្អុយ ។
- ចាក់ ប្រូស្តាក្លង់ឌីន (Dinolytic, Suiprost) ដើម្បីជំរុញឱ្យបញ្ចេញវត្ថុកខ្វក់ ។
- ចាក់អង់ទីប៊ីយ៉ូទិក ៥ ថ្ងៃ (Trimetoprim + Sulfa or Amoxicillin)
- លាយម្សៅ Amoxicillin ក្នុង ១00មល ទឹករួចចាក់ចូលក្នុងស្បូន ។
- *មិនត្រូវចាក់ទឹកជាមួយ Iodin ទៅក្នុងស្បូនទេ ។*

# II . កូនជ្រូកធំហើយធ្ងន់

# ១. កូនជ្រូកថ្លោសនៅពេលកើត

## ១.១. ការផ្តល់ចំណីសំរាប់មេជ្រូកធើម

គោលការណ៏ងាយៗសំរាប់ការផ្តល់ចំណី

- ការវិវត្តន៏របស់សុកក្នុងពេល១២-២៥ ថ្ងៃដំបូងក្រោយពេលដាក់ឈ្មោលអាចជួយអោយយើងកំណត់ពីគុណភាពរបស់កូនជ្រូកនៅដំណាក់កាលចុងក្រោយនៃការធើម ។ សុកដែលមានទំហំតូចនឹងចូលរួមចំនែកធ្វើអោយកូនជ្រូកមានទំហំតូចដែរ ។
- វាមានសារៈសំខាន់ណាស់ដោយត្រូវផ្តល់ចំណីទៅអោយមេជ្រូកដើម្បីថែរក្សារូបរាងដោយប្រើប្រាស់របបចំណីរបស់មេធើមដោយចប់បន្ទាប់ពី ២១ ថ្ងៃ ដោយប្រើ ៣ គក្រ ឬ ច្រើនជាងនេះ ។
- វាជាការចំាបាច់ណាស់ដែលត្រូវលាយចំណីជាមួយប្រេម៉ិចដែលមានវីតាមីននិងរ៉ែ ដើម្បីធានាការលូតលាស់ល្អនៃកូនក្នុងពោះ
- វាមានសារៈសំខាន់ណាស់សំរាប់ការបន្ថែមការផ្តល់ចំណីក្នុងពេល ២អាទិត្យចុងក្រោយដើម្បីធ្វើអោយកូនជ្រូកថ្លោស ហើយនឹងការពារការក្បៀនលាមក ។
- *ប៉ុន្តែមេជ្រូកធាត់ពេកវានឹងប្រឈមមុខទៅនឹងបញ្ហានៅពេលកើតកូន កូនកើតមកឃើត និងខាតបង់លុយឥតប្រយោជន៏ ។*

# ១. កូនជ្រូកកាន់តែថ្លោសនៅពេលកើត

## ១.១. ការផ្តល់ចំណីសំរាប់មេជ្រូកដើម

**រូបរាងរបស់មេជ្រូកដែលល្អនៅមុនពេលកើតកូន : រូបរាងទី ៣ ល្អជាងគេបំផុត**

រូបរាងទី ២



រូបរាងទី ៣



រូបរាងទី ៤



រូបរាងទី ៥



# ១. កូនជ្រូកកាន់តែថ្លោសនៅពេលកើត

## ១.២. ពូជល្អ

ពូជល្អ

- ពូជវាបានផ្សាភ្ជាប់ទៅនឹងទំងន់របស់កូនជ្រូកនៅពេលកើតផងដែរ
- ពូជវាបានផ្សាភ្ជាប់ទៅនឹងទំហំប៉ុនៗគ្នារបស់កូនជ្រូកនៅពេលកើតផងដែល
- ពូជវាបានផ្សាភ្ជាប់ទៅនឹងអត្តចរិកស្លូតបូតរបស់មេផងដែរ
- ពូជវាបានផ្សាភ្ជាប់ទៅនឹងសម្ថភាពផលិតទឹកដោះរបស់មេ
- ពូជវាបានផ្សាភ្ជាប់ទៅនឹងគុណភាពរបស់ក្បាលដោះ
- ការប្រើប្រាស់ការបង្កាត់សប្បនិម្មិតជាមួយទឹកកាមជ្រូកបាដែលយើងជ្រើរើសវាក៏អាចជួយអោយយើងទទួលបាននូវកូនជ្រូកដែលកើតមកថ្លោសដែរ

# ១. កូនជ្រូកកាន់តែថ្លោសនៅពេលកើត

## ១.២. ពូជល្អ

កូនជ្រូកចំនួន ១៤ ដែលមានធំហាំប៉ុនៗគ្នាដែលមានអាយុ ២ថ្ងៃ



# ២.   កូនជ្រូកកាន់តែធ្ងន់នៅពេលផ្តាច់ដោះ

## ២.១.   ការផលិតទឹកដោះ

- នៅពេលដែលមេជ្រូកផលិតទឹកដោះបានគ្រប់គ្រាន់យើងនឹងឃើញកូនជ្រូកធ្ងន់ល្អ និង ហើយពួកវានឹងនៅស្ងៀមស្ងាត់ ព្រមទាំងកន្ទេរាមដោះស្ថិតក្នុងសភាពល្អ និង ពេញទៅដោយទឹកដោះ។



# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្តាច់ដោះ

## ២.១. ការផលិតទឹកដោះ

### កន្សោមដោះ

- ដោះដែលមានទំរង់ និង មានមុខងារល្អគឺអាចចិញ្ចឹមកូនជ្រូកអោយរស់បានច្រើនដោយមិនត្រឹមតែផ្តល់នូវទឹកដោះដំបូង (កូឡូស្រ្តូម) និង ទឹកដោះប៉ុណ្ណោះទេតែថែមទាំងផ្តល់អោយកូនជ្រូកនូវភាពងាយស្រួលសំរាប់ការបៅទៀតផង។
- ក្បាលដោះដែលសមល្អ  គឺ លេខ ១ ២ និង ៣




1, 2, 3 Functional

- ចំនួនក្បាលដោះ: យ៉ាងតិចត្រូវមានក្បាលដោះចំនួន ១២ជាចាំបាច់
- ទំហំក្បាលដោះ : នៅពេលខ្លះកូនជ្រូកមានទំហំតូច ហើយក្បាលដោះមានទំហំធំពេកដូនេះកសិករត្រូវជួយកូនជ្រូកអោយបៅទឹកដោះដំបូងអោយបានគ្រប់គ្រាន់ ចាប់ពីប៉ុន្មានម៉ោងដំបូង។

# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្តាច់ដោះ

## ២.១. ការផលិតទឹកដោះ

- ក្បាលដោះដែលធម្មតា



- ក្បាលដោះដែលមិនធម្មតា



# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្តាច់ដោះ

## ២.១. ការផលិតទឹកដោះ

### ការចិញ្ចឹម

- <u>ការផ្តល់ទឹក</u>

យ៉ាងតិច ៤៥ លីត្រសំរាប់មួយថ្ងៃ ហើយច្រើនជាងនេះនៅពេលក្តៅ ។ ពេលខ្លះ ថ្ងៃទីមួយបន្ទាប់ពីកើតកូន មេជ្រូកប្រឈមមុខនឹងបញ្ហាក្នុងការក្រោកឈរ ដូចនេះវាចាំបាច់ណាស់សំរាប់យើងសំរួលការផឹកទឹករបស់មេជ្រូក ។

- <u>ការផ្តល់ចំណី</u>

កសិករត្រូវបន្ថែមជាតិសាច់ ( ប្រូតេអ៊ីន) ក្នុងរបបអាហារដើម្បីជួយដល់ការផលិតទឹកដោះ គាត់អាចប្រើសណ្តែកសៀង ម្សៅត្រី ហើយនិង ប្រេម៉ិចដែលមានជាតិវីតាមីន និង រ៉ែ ។

កសិករត្រូវផ្តល់ចំណីដែលមានគុណភាពល្អដោយអាស្រយ័ទៅនឹងចំនួនកូនជ្រូកដែលមាន ។ ប្រើ ៥ គក្រ ចំពោះ មេដែលមានកូន៦-៧ ប៉ុន្តែ ៧ គក្រ បើមេមានកូនច្រើនជាង ១០ ។ បើនៅពេលក្តៅខ្លាំងមេជ្រូកមិនអាចស៊ីបានឆ្អែតទេ និងការផលិតទឹកដោះក៏មិនគ្រប់គ្រាន់ដែរ ដូចនេះត្រូវអោយវាស៊ីអោយបាន ៣ ឬ ៤ ពេល ។

# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្ដាច់ដោះ

## ២.១. ការផលិតទឹកដោះ

ការផលិតទឹកដោះបានល្អ កូនជ្រូករឹងមាំ





# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្តាច់ដោះ

## ២.១. ការផលិតទឹកដោះ

**ព្យាបាលដោះមិនប្រក្រតី៖ លាសដោះ**

- លាសដោះនាំអោយមានថយចុះនៃការផលិតទឹកដោះ និង កូនជ្រូកខ្សោយ
- ផ្លូវចូលរបស់មេរោគ (បាក់តេរី) គឺតាមរយៈរន្ធរបស់ក្បាលដោះ រឺ ការចាក់ចូលទៅក្នុងក្រពេញ ដោយធ្មេញដ៏ស្រួចរបស់កូនជ្រូក។ កាត់ធ្មេញកូនជ្រូក និង លាងសំអាតដោះ ជាមួយសាប៊ូ។
- អឺ កូលី គឺជាមូលហេតុរួមប៉ុន្តែ ស្តាហ្វីឡូកូកស៊ី ហើយ ស្ត្រីបតូកូកស៊ី អាចរាតត្បាតផងដែរ៖ ចាំបាច់ត្រូវជ្រើរើស អង់ទីប៊ីយ៉ូទិចមកប្រើ
- ជាទូទៅប្រភពនៃមេរោគត្រូវបានចំលងនៅតាមបរិយាកាស៖ ចាំបាច់ណាស់ត្រូវសំអាត និង សំលាប់មេរោគនៅតាមទ្រុង។ សំខាន់ បំផុតត្រូវលាយ ក្លរីន ទៅក្នុងទឹក ព្រោះវាជារឿយៗត្រូវបានចម្លងផងដែល។

<u>ការធ្វើរោគវិនិច្ឆ័យ</u>

- មេជ្រូកឈប់ស៊ី ភ្នែកឡើងពណ៌ក្រហម ក្តៅលើសពី ៤០ អង្សា សេ
- ចំពោះការធ្វើរោគវិនិច្ឆ័យ ពេទ្យសត្វភូមិត្រូវស្ទាបដោះ ដើម្បីរកមើលកន្លែងហើម និង ដុំ។

# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្ដាច់ដោះ

## ២.១. ការផលិតទឹកដោះ

- លាសដោះ



- ក្បាលដោះស្ថិតបន្ទាប់ពីលាស



# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្តាច់ដោះ

## ២.១. ការផលិតទឹកដោះ

- ទឹកដោះមិនគ្រប់គ្រាន់



- ទឹកដោះគ្រប់គ្រាន់



# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្តាច់ដោះ

## ២.១. ការផលិតទឹកដោះ

**ការព្យាបាលលាសដោះ**

- អុកស៊ីតុកស៊ីនដើម្បីជំរុញទឹកដោះ (0.៥ មល ចាក់ចូលសសៃឈាម)
- អង់ទីប៊ីយ៉ូទិក: ទ្រីមេ៉តូព្រីម/ស៊ុលហ្វា អង់រ៉ូផ្លុកសាក់ស៊ីន
- ករណីធ្ងន់ធ្ងរត្រូវចាក់ ២ ដងក្នុងមួយថ្ងៃ
- ចាក់ថ្នាំប្រឆាំងការរលាក (ដិចសាមេតាសូន) បើសិនជាដោះនោះរឹង

*លាសដោះ អាចរកឃើញក្នុងកំឡុងប៉ុន្មានថ្ងៃមុនកើតកូន ហើយត្រូវព្យាបាលដោយអង់ទីប៊ីយ៉ូទិក ប៉ុន្តែមិនត្រូវចាក់ដិចសាមេតាសូនទេ។*

<u>ការការពារ</u>

- ត្រូវធ្វើអនាម័យ និង សំអាតទឹកជាមួយ ក្លរិន
- មិនត្រូវប្រើអាចម៍រណាសំរាប់អោយជ្រូកដេកទេ ព្រោះបើវាសើមដោយទឹកនោមនោះវាជាកន្លែងសំរាប់ការវិវត្តន៍នៃមេរោគ។
- លាយចំណីជាមួយអង់ទីប៊ិយ៉ូទិកសំរាប់អោយស៊ី ៣-៥ថ្ងៃមុនពេលកើតកូន។ ប្រើ ទ្រីមេតូព្រីម/ស៊ុលហ្វា ឬ ភ្លូយមេ៉គីន។

# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្តាច់ដោះ

## ២.២. ការបង្ការ និង ព្យាបាលជំងឺរាំរៃ

**កូស៊ីឌីយ៉ូស៊ីស**

- កូស៊ីឌីយ៉ូស៊ីសកើតមាននៅអាយុពី ៧-២១ ថ្ងៃបន្ទាប់ពីការកើត
- បង្ករអោយមានខ្លាំង និង មានពណ៌ប្រផេះ
- កូនជ្រូកមិនងាប់ទេ តែទំងន់ថយចុះ រោមមិនល្អ ហើយបណ្តាលអោយមានរាងស្គមស្គាំងនៅពេលផ្តាច់ដោះ។

ការព្យាបាល

- អង់ទីប៊ីយ៉ូទិកមិនសូវមានប្រសិទ្ធភាពទេសំរាប់ជំងឺកូកស៊ីឌីយ៉ូ មានតែ ស៊ុលហ្វាឌីមីឌីន (ស៊ុលហ្វា ៣៣) ដែលមានប្រសិទ្ធភាពខ្ពស់

ការការពារ

- ទ្រុងត្រូវស្ងួតជានិច្ច
- ត្រួតពិនិត្យសត្វរុយ និង មូស។
- បើអាចម៍រណារ ក្រណាត់ប្រើសំរាប់សំបុកកូនជ្រូក មិនត្រូវប្រើវាទៀតទេ
- ប្រសិទ្ធភាពបំផុតនោះគឺត្រូវប្រើ តុលត្រាស៊ុលរី (អង់ទីកុក/ បេកុក រយៈពេល ៣ថ្ងៃបន្ទាប់ពីកើត

# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្តាច់ដោះ

## ២.២. ការបង្ការ និង ព្យាបាលជំងឺរ៉ាំរ៉ៃ

### កុស៊ីឌីយ៉ូស៊ីស

មានរាគខ្លាំង



គូថប្រឡាក់



ការការពារ



# ២.   កូនជ្រូកកាន់តែធ្ងន់នៅពេលផ្តាច់ដោះ

## ២.២.   ការបង្ការ  និង  ព្យាបាលជំងឺរ៉ាំរ៉ៃ

**ជំងឺសន្លាក់**

- ពេលខ្លះយើងឃើញកូនជ្រូកដេកដោយមិនបានបង្ហាញអាការៈឈឺជើងទេដោយគ្រាន់តែឃើញស្បែករលាត់តិចតួចខុសធម្មតាតែបើយើងធ្វើអោយកូនជ្រូកងើបឈនោះវានឹងបង្ហាញសភាពខ្ជកជាមិនខាន ។ ដូចនេះពេលពិនិត្យកូនជ្រូកកំពុងដេកត្រូវដាស់វាអោយងើប ។
- ការខ្ជកជើង និង ហើមសន្លាក់វាស្ដែងចេញនៅពេលកូនជ្រូកផ្លាស់ទី
- វាស្ដែងចេញចាប់ពី ៣-១៥ ថ្ងៃ

ការការពារ

- ពិនិត្យក្នុងមាត់កូនជ្រូកដើម្បីមើលថាវាគ្មានការចំលងនៅពេលដែលកាត់ធ្មេញ
- ពិនិត្យរកមើលដំបៅរលួយរបស់កូនជ្រូក ជាពិសេសការដាច់នៅលើជង្គង់ ជើង ឬកន្ទុយ ។
- ប្រើម្ជុលដែលស្អាតសំរាប់ចាក់ជាតិដែកចូល

ការព្យាបាល

- អាម៉ុកស៊ីលីន LA ជាមួយឡាំងកូមីស៊ីន ប្រសិនសន្លាក់ឡើងក្ដៅខ្លាំង ហើយហើម
- ដិចសាមេតាសូនអាចចាក់បានតែម្ដង

# ២. កូនជ្រូកកាន់តែធំនៅពេលផ្តាច់ដោះ

## ២.២. ការបង្ការ និង ព្យាបាលជំងឺរាំរៃ

ដំបៅដែលបណ្តាលអោយឈឺសន្លាក់៖ ខូកជើង និង ហើមសន្លាក់







# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្តាច់ដោះ

## ២.២. ការបង្ការ និង ព្យាបាលជំងឺរាំរៃ

**ជំងឺដែលលេចឡើងនៅលើស្បែក (ស្តាភីឡូកូកុស)**

ជាទូទៅវាចាប់ផ្តើមជាមួយចំណុចតូចៗនៅរង្វង់មុខនិង ជើង។ ស្បែកតាមណ្តោយពោះ ឆ្អឹងជំនីរ និងចន្លោះជើង ប្រែពណ៌ទៅជាត្នោតបន្តិចម្តងពេញទាំងរាងកាយ។ ស្បែកមានសភាពជ្រីវជ្រួញជាផ្នត់ៗហើយបើយើងស្ទាបវា និង មានសភាពដូចជាប្រឡាក់ខ្លាញ់។



- ការព្យាបាលមិនសូវមានប្រសិទ្ធភាពទេ។ ចាក់អាម៉ុកស៊ីលីន ជាមួយ ឡាំងកូមិស៊ីន និង ជាការប្រសើរដោយប្រើសារធាតុសំលាប់មេរោគដែលមានកំហាប់ទាបលើស្បែក។

# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្ដាច់ដោះ

## ២.២. ការចិញ្ចឹមកូនជ្រូកកំពុងបៅដោះ

- ពេលកូនជ្រូកមានអាយុលើសពី ៣ អាទិត្យ ទឹកដោះមេជ្រូកមិនអាចធានបានសំរាប់ការលូតលាស់របស់វាទេ។
- ដើម្បីទទួលបានកូនជ្រូកដែលធ្ងន់ជាការចាំបាច់ត្រូវចាប់ផ្ដើមផ្ដល់ចំណីពិសេសទៅអោយកូនជ្រូក ( ប្រូតេអ៊ីនខ្ពស់ និងងាយរំលាយ) ។
- ជាការល្អត្រូវផ្ដល់ចំណីពិសេសដែលផលិតដោយក្រុមហ៊ុនល្បីដូចជា ( សីភី បែលតាក្រូ) ។ ការចំណាយមិនសូវខ្ពស់ប៉ុន្មានទេ ព្រោះកូនជ្រូកស៊ីពី ៥០០ ក្រ- ១ គក្រ ក្នុងកំឡុងពេល១អាទិត្យចុងក្រោយមុនពេលផ្ដាច់ដោះ។ កសិករមិនត្រូវខ្ជះខ្ជាយចំនីទេត្រូវអោយវាស៊ីម្ដងបន្តិចៗតែច្រើនដង។
- ចំណុចល្អផ្សេងទៀតនៃការផ្ដល់ចំណីមុនពេលផ្ដាច់ដោះគឺវាបានធ្វើអោយកូនជ្រូករៀនរំលាយអាហារ និងមិនគ្រាន់តែទឹកដោះទេ។ វានឹងមានភាពរលូននៅពេលផ្ដាច់ដោះ។

# ២. កូនជ្រូកកាន់តែធ្ងន់នៅពេលផ្តាច់ដោះ

## ២.២. ការចិញ្ចឹមកូនជ្រូកកំពុងបៅដោះ

ដាក់ចំណីក្នុងបរិមាណតិចអោយសមទៅនឹងស្តុកដើម្បីជៀសវាងការខ្ជះខ្ជាយ



